# ម្តេចក៏ សាធារណរដ្ឋខ្មែរ ?

## ការប្រទាញប្រទង់គ្នា



រូបថត ពិធីបុណ្យ នៃ កំណើត នៃ សាធារណរដ្ឋខ្មែរ នៅ ថ្ងៃទី៩ តុលា ១៩៧០

ស៊ីសុវត្ថិ សិរិមតៈ - លន់ នល់ - អ៊ិន តាំ

**សរសេរ ដោយ ឧប សៅ សង្ហា**

គ្មាន រក្សាសិទ្ធិ អ្នកនិពន្ធ

# ម្ដេចក៏ សោកនាដកម្មខ្មែរ ?

## ការប្រទាញប្រទង់គ្នា

## មាតិការឿង


សេចក្ដីផ្ដើម .......... 3

ការប្រទាញប្រទង់គ្នា .......... 5

រដ្ឋសភា .......... 5

កាលប្រវត្តិ .......... 5

នៅក្រោយ ឆាកល្ខោន នៃ រដ្ឋសភាធម្មនុញ្ញ .......... 12

ហង្ស ធុន ហាក់ - លន់ ណុន .......... 18

ទ្រង់ សិរិមតៈ .......... 31

និទានខ្លីៗ (anecdote) .......... 33

ការបោះឆ្នោត .......... 38

ការបោះឆ្នោត ជ្រើសរើស ប្រធានាធិបតី .......... 38

ការបោះឆ្នោត រើសតំណាងរាស្ត្រ .......... 43

សេចក្ដីសន្និដ្ឋាន .......... 48

# ម្តេចក៏ សោកនាដករដ្ឋខ្មែរ ?

## ការប្រណាញប្រទង់គ្នា

## សេចក្តីផ្តើម

នៅថ្ងៃ ទី១៨ មីនា ឆ្នាំ ១៩៧០ សភាជាតិ បានបោះឆ្នោត ទំលាក់សម្តេច សីហនុ ពី តំណែង ប្រមុខរដ្ឋ។ ដំណឹងនេះ ត្រូវបាន វិទ្យុជាតិ ប្រកាស ជាសាធារណៈ នៅម៉ោង ១៣,៣០។ នៅថ្ងៃ ទី ១៩ មីនា លោក លន់ លន់ ដាក់ ឱសានវាទ ឱ្យ កងទ័ព យៀកកុង និង យួនខាងជើង ដកចេញ ពី ស្រុកខ្មែរ ក្នុង រយៈពេល ៤៨ ម៉ោង។ នៅថ្ងៃ ជាមួយគ្នានោះដែរ សម្តេច សីហនុ ប្រកាស តាមវិទ្យុ ពី ទីក្រុងប៉េកាំង សូមឱ្យ ប្រជាពលរដ្ឋខ្មែរ ងើប បះបោរជាទូទៅ ប្រឆាំងនឹង រដ្ឋាភិបាលលោក លន់ នល់។ នៅថ្ងៃ ទី២០ មីនា សហរដ្ឋអាមេរិក ទទួលស្គាល់ ជា ផ្លូវការ របបថ្មីខ្មែរ ដឹកនាំដោយ រាជរដ្ឋាភិបាល ស្រោចស្រង់ជាតិ។ នៅថ្ងៃ ទី ២៣ មីនា សម្តេច ប្រកាសចំពោះ អ្នកតស៊ូខ្មែរ គ្រប់និន្នាការ រួមគ្នា បង្កើត រណសិរ្ស រួបរួមជាតិ នៃ កម្ពុជា (FUNK[1])។ នៅថ្ងៃ ទី ២៩ មីនា កងទ័ព យៀកកុង និង យួនខាងជើង ដែលមកនៅ តាំងទីនៅ ស្រុកខ្មែរ តាំងពីឆ្នាំ ១៩៦៥ ដោយមាន ការ អនុញ្ញាត ពី សម្តេច សីហនុ បានបើក ការវាយប្រហារ មកលើ ទីតាំង កងទ័ពជាតិខ្មែរ ទូទាំងប្រទេស ដោយគ្មាន ធ្វើការ ប្រកាសជាមុន។ ពីថ្ងៃ ទី៣ ដល់ ៥ ឧសភា សម្តេច សីហនុ ធ្វើ

[1] FUNK : Front Uni National du Kampuchéa.

# ម្ដេចក៏ សាធារណរដ្ឋខ្មែរ ?

## ការប្រទាញប្រទង់គ្នា

សាមាជមួយ នៅ ទីក្រុងប៉េកាំង ដើម្បី បង្កើត រាជរដ្ឋាភិបាល បង្រួបបង្រួមជាតិ កម្ពុជា (GRUNK)[2] នៅក្នុងនោះ មាន សមាសភាព បីក្រុមចូលរួម ៖ ពួក អ្នកសីហនុនិយម, ពួក ខ្មែរក្រហម និង ពួក ខ្មែរយៀកមិញ[3]។ រាជរដ្ឋាភិបាលនោះ ដឹកនាំដោយសម្ដេច សីហនុ។ នៅថ្ងៃ ទី២១ ឧសភា លោក លន់ នល់ ប្រកាសតាមវិទ្យុជាតិ ថា តាម សេចក្ដីប្រាថ្នា របស់ប្រជាពលរដ្ឋខ្មែរ របបដឹកនាំថ្មី នឹងរៀបចំ បង្កើត របប សាធារណរដ្ឋ នៅពេលដ៏ឆាប់រហ័សមួយ។

ការបង្កើត នៃ របប សាធារណរដ្ឋ នេះឯង ដែល យើង តាមដាន ពិនិត្យមើល នៅក្រោយ ឆាកល្ខោន (coulisse) ថា តើ វា មាន ការប្រទាញប្រទង់គ្នា បែបណា រវាង ក្រុម ផ្សេងៗ ដែល មាន ការពាក់ព័ន្ធ នៅក្នុង ព្រឹត្តិការណ៍ ថ្ងៃ ទី១៨ មីនា ឆ្នាំ ១៩៧០។ ក្រុម ទាំងនោះ មាន ៖ រដ្ឋសភា, ទ្រង់ សិរិមតៈ និង សម្ព័ន្ធភាព របស់ លោក ហង្ស ធុន ហាក់, លន់ ណុល និង លោក កេង វ៉ាន់សាក់។ សួរ ថា តើ ការប្រទាញប្រទង់គ្នានោះ វា មាន កំរិតប៉ុណ្ណា ៖ ជា ជម្លោះ នៃ គំនិត ឬ ជា ការប្រឆាំងគ្នា ផ្ដាច់ប្ដូរ (opposition radicale) ?

---

[2] GRUNK : Gouvernement Royal d’Union National du Kampuchéa.
[3] ខ្មែរយៀកមិញ ៖ ពួក ខ្មែរកុម្មុយនិស្ត និយមយួនកុម្មុយនិស្ត។

# ការប្រទាញប្រទង់គ្នា

## រដ្ឋសភា

### កាលប្បវត្តិ

នៅក្នុង ព្រឹត្តិការណ៍ ថ្ងៃ ទី១៨ មីនា ឆ្នាំ ១៩៧០, រដ្ឋសភា មាន តួនាទី ដ៏សំខាន់មួយ ព្រោះ រដ្ឋាភិបាល ស្រោចស្រង់ជាតិ ជ្រើសរើស ផ្លូវច្បាប់ សំរាប់ ទំលាក់ សម្តេច សីហនុ ពីមុខ តំណែង ដើម្បី ចង់ជៀសវាង ប្រើ មធ្យោបាយ នៃ រដ្ឋប្រហារ។ កត្តា បីយ៉ាង ដែល រដ្ឋាភិបាល អាចមាន ជំនឿ ជាក់ច្បាស់ ទៅលើ រដ្ឋសភា ថា នឹងធ្វើសហការ ជាមួយខ្លួន ៖ ១. រដ្ឋសភានោះ កើតចេញ ពី ការបោះឆ្នោត ដោយ សេរី និង យុត្តិធម៌ ព្រោះ ប្រជាពលរដ្ឋ ជ្រើស រើសផ្ទាល់ បេក្ខជន តំណាងរាស្ត្រ ដែល ជាបេក្ខជនសេរី មិនដូចពេលមុនៗ គឺថា ចលនា សង្គមរាស្ត្រនិយម ជា អ្នកសម្រាំង បេក្ខជនមួយចំនួន ក្នុង ចំណោម នៃ សមាជិក នៃ ចលនា យកមកឱ្យ ប្រជាពលរដ្ឋ ជ្រើសយក អ្នកណាម្នាក់ ទោះបី នៅក្នុងចំណោមនោះ ខ្លួនមិនសូវពេញចិត្ត លើអ្នកទាំងនោះក៏ដោយ, ដូច្នេះ រដ្ឋសភានោះ គឺ ពិត ជា មានគំនិត ជាតិនិយម ទុកប្រយោជជាតិ ជា អាទិភាព, ២. សម្តេចសីហនុ ទុក រដ្ឋសភានោះ ជា សត្រូវ នឹងព្រះអង្គ, ដូច្នេះ រដ្ឋសភានោះ ច្បាស់ ជា ជ្រើសរើស យកខាង រដ្ឋាភិបាល ជា មិត្ត នៅក្នុង

# ម្ដេចក៏ សោណារឈារដ្ឋខ្មែរ ?

## ការប្រណាញ់ប្រណង់គ្នា

វិវាទ រវាង រដ្ឋាភិបាល នឹង សម្ដេច សីហនុ, ៣. រដ្ឋសភានោះ មាន និន្នាការ នៃ សេរីនិយម ដែល ច្បាស់នឹង បន្តគាំទ្រ នយោបាយ សេដ្ឋកិច្ចសេរី របស់ រដ្ឋាភិបាល ដែល ជា មធ្យោបាយ សមល្អ សំរាប់ ដោះស្រាយ វិបត្តិ សេដ្ឋកិច្ច, ដូច្នេះ នៅក្នុង គំនិត សេរីនិយមនេះឯង ដែល រដ្ឋសភានោះ គ្មាន ហេតុផលអ្វី នឹងគាំទ្រ នយោបាយ សេដ្ឋកិច្ច សង្គមនិយម របស់សម្ដេច សីហនុ ដែល បង្ហាញ ជាក់ស្ដែង ពី ភាពទ្បងចុង ដែល នាំឱ្យព្រះអង្គ បង្កើត រដ្ឋាភិបាល ស្រោចស្រង់ជាតិ ដើម្បី ស្ដារ ស្ថានភាព អសោចនោះ, ដូច្នោះទេឬ ?

ប៉ុន្តែ រដ្ឋសភានោះ មាន មោទនភាព ថា ខ្លួន ជា ស្ថាប័នជាតិ ពិតប្រាកដ ដែល ជា អ្នកកាន់កាប់ អំណាច នីតិបញ្ញាតិ ច្បាស់ ជា ស្វែងរក តួនាទី របស់ខ្លួន នៅក្នុង ការកសាង របបដឹកនាំ ថ្មី សំរាប់ វិបុលភាព នៃ ប្រជាជាតិខ្មែរ។ ដូច្នេះ សហការ ជាមួយ រដ្ឋាភិបាល នៅក្នុង គោលការណ៏នេះ វា តម្រូវឱ្យ រដ្ឋាភិបាល គោរព យ៉ាងពេញលេញ រដ្ឋធម្មនុញ្ញ ជាធរមាន រហូត ដល់មាន រដ្ឋធម្មនុញ្ញថ្មី, ដូច្នេះ រដ្ឋសភា ជា អ្នកឱ្យ សុពលភាព នៃ ការ ប្រកាស នៃ ភាពអាសន្ន របស់ ការស្នើសូម ពី រដ្ឋាភិបាល នៅ ក្នុង ដែនច្បាប់ ដ៏តឹងរឹង នៃ រដ្ឋធម្មនុញ្ញ ជាធរមាន។ ហើយ នៅក្នុង រដ្ឋសភា វា មិនខ្វះ វាគ្មិន សំខាន់ៗ តាមដាន ពិនិត្យ សកម្មភាព នៃ រដ្ឋាភិបាល ដូចយ៉ាង លោក អ៊ិន តាំ (ប្រធាន

# ម្ដេចក៏ សាធារណរដ្ឋខ្មែរ ?

## ការប្រណាញប្រណង់គ្នា

រដ្ឋសភា ស្ដីទី, ជា អ្នកកលយុទ្ធសភា (grand tacticien parlementaire) ដ៏ល្បីល្បាញ, ស៊ីម វ៉ា (នយជន[4] ជើងចាស់ ហ៊ាន មិនដែល សំចៃ សំដី សំរាប់ ការពារ សច្ចៈភាព), ឌុក រ៉ាស៊ី (អ្នកច្បាប់ មានការពិសោធ និង ជា ជន មាន គតិ ឯករាជ្យ), អ៊ឹង ម៉ឹង (សាស្ត្រាចារ្យ នីតិសាស្ត្រ មាន គតិ ឆ្លាតវៃ សំរាប់ ពន្យល់ និមិត្តហេតុ (subtilité) នៃ ច្បាប់ ឱ្យស្រួលយល់) ហើយនឹង តំណាងរាស្ត្រមួយចំនួនទៀត ជា មេក្រុមតូចៗ មាន សុរោហារ ដូចជា លោក ថាច់ ចាន់, ឯក ឃុំអុន ។ល។ អ្នកទាំងនោះ មិនសូវ មាន ចិត្តផ្អែមល្ហែមនឹង រដ្ឋាភិបាលនោះឡើយ ហើយ តែងតែ រិះគន់ លើ សកម្មភាពណា ដែល វា មាន ភាព អនិយ័ត[5]។ ក្រោយពី បោះឆ្នោត ទំលាក់ សម្ដេច សីហនុ ពីមុខតំណែងមក នៅថ្ងៃ ទី២៧ មីនា ឆ្នាំ ១៩៧០ តំណាងរាស្ត្រ ពីររូប នៅ មណ្ឌល ក្នុង ខេត្ត កំពង់ចាម ត្រូវ ពួកអ្នកបះបោរ សីហនុនិយម វាយ រហូតដល់ស្លាប់ ហើយ វះយកថ្លើម ទៅដណ្ដាំស៊ី នៅទី ផ្សារ នៃ ទីក្រុងកំពង់ចាម, បន្ទាប់មក នាំគ្នា បង្ខំ ឱ្យឡានឈ្នួល ជា ច្រើនគ្រឿង ដឹកជញ្ជូន ពួកខ្លួន មកកាន់ ទីក្រុងភ្នំពេញ ដើម្បី វាយប្រហារ រដ្ឋាភិបាល និង រដ្ឋសភា។ នៅក្នុង ស្ថានការនោះ នៅថ្ងៃ ទី២៨ មីនា រដ្ឋសភា អនុម័ត ច្បាប់ ‹ប្រទេស ជួបប្រទះនឹង ភាពអាសន្ន› ផ្ដល់ អំណាចពេញលេញ ឱ្យ រដ្ឋាភិបាល ចាត់ការបញ្ហានេះ។ នៅថ្ងៃ ទី១៩ ឧស

---

4 នយជន : អ្នកនយោបាយ។

5 អនិយ័ត :មិនស្មើជ្រុង, ផ្ទុយពីសីលធម៌, មិនទៀងទាត់។

# ម្តេចក៏ សាធារណរដ្ឋខ្មែរ ?

## ការប្រណាញប្រខំគ្នា

ភា រដ្ឋសភា បង្កើត មជ្ឈមណ្ឌលជាតិ សម្រាប់ ការប្រមូល ព័ត៍មាន ទូទាំងប្រទេស បាន មកពី ប្រជាពលរដ្ឋ។

ក្រោយ ពីការវាយប្រហារ កងទ័ព យួនខាងជើង និង យៀកកុង មកលើ កងទ័ពជាតិ, នៅថ្ងៃ ទី១៦ មិថុនា ឆ្នាំ ១៩៧០ រដ្ឋសភា បានបង្កើត គណកម្មាធិការ ប្រតិបត្តិ ដើម្បី តាមពិនិត្យ ការវិវត្តន៍ នៃ ស្ថានការ នយោបាយ និង យោធា នៅក្នុង ប្រទេស, តែគណកម្មាធិការនោះ ត្រូវបាន រំលាយវិញ នៅ ថ្ងៃទី ៣ សីហា។

នៅថ្ងៃ ទី២៧ មិថុនា ឆ្នាំ ១៩៧០ រដ្ឋសភា ផ្តល់ ទំនុកចិត្តពេញលេញ ជូន លោក លន់ នល់ និង ទ្រង់ សិរិមតៈ ដើម្បី ដោះស្រាយ បញ្ហា នយោបាយ និង សង្គ្រាម ដែល កំពុង កើតឡើង នៅ ស្រុកខ្មែរ។

នៅថ្ងៃ ទី២៩ សីហា ឆ្នាំ ១៩៧០ សភាជាតិ ផ្សាយ គំរោង នៃ រដ្ឋធម្មនុញ្ញ ដែល មាន លោក អ៊ុំង ម៉ុង ជា នាយកគំនិត។ នៅថ្ងៃ ទី២៥ កញ្ញា រដ្ឋសភា បោះឆ្នោត បន្ត រយៈពេល ៦ ខែ ទៀត ដាក់ ប្រទេស នៅក្នុង ភាពអាសន្ន។

នៅថ្ងៃ ទី៥ តុលា ឆ្នាំ សហសភា (រដ្ឋសភា និង ក្រុមប្រឹក្សា ព្រះរាជាណាចក្រ) ធ្វើការប្រជុំរួម ដើម្បី ពិនិត្យ អំពី គំរោង បង្កើត សាធារណរដ្ឋខ្មែរ។

# ម្ដេចក៏ សាធារណរដ្ឋខ្មែរ ?

## ការប្រែឆាញប្រែឆខ្លួន

នៅថ្ងៃ ទី៧ តុលា ឆ្នាំ ១៩៧០ សហសភា បោះឆ្នោត បង្កើត សាធារណរដ្ឋខ្មែរ ហើយ នៅថ្ងៃ ទី៩ តុលា មាន ធ្វើពីធី កំណើត នៃ របបថ្មីនោះ នៅមុខ ព្រះបរមរាជវាំង។

នៅថ្ងៃ ទី២៣ វិច្ឆិកា ឆ្នាំ ១៩៧០ លោក ចេង ហេង, ប្រមុខរដ្ឋ, ប្រកាស បន្ត អាណត្តិ នៃ រដ្ឋសភា។

នៅថ្ងៃ ទី២០ មេសា ឆ្នាំ ១៩៧១ រដ្ឋសភា បង្កើត គណកម្មការ ចំរុះ ទូលាយ ដើម្បី តាក់តែ រដ្ឋធម្មនុញ្ញ។ លោក លន់ នល់[6] លាលែង ពី តំណែង នាយករដ្ឋមន្ត្រី, ទ្រង់ សិរិមតៈ បន្ត ដឹកនាំ គណរដ្ឋមន្ត្រី ក្នុង ឋានៈ ជា នាយករដ្ឋមន្ត្រី ប្រតិភូ។

នៅថ្ងៃ ទី២១ មេសា ឆ្នាំ ១៩៧១ រដ្ឋសភា បានលើកដំកើង លោក លន់ នល់ ជា សេនាប្រមុខ ហើយ នៅថ្ងៃ ទី៣០ មេសា លោក ត្រូវ រដ្ឋាភិបាល តែងតាំង ជា អគ្គនាយសេនាធិការ នៃ កងទ័ព ជាតិខ្មែរ។

នៅថ្ងៃ ទី៦ ឧសភា ឆ្នាំ ១៩៧១ លោក លន់ នល់ ត្រូវតែងតាំង ជា នាយករដ្ឋមន្ត្រី ជាថ្មី, ទ្រង់ សិរិមតៈ ជា នាយករដ្ឋមន្ត្រី ប្រតិភូ និង លោក អ៊ិន តាំ ជា ឧបនាយករដ្ឋមន្ត្រី។ នៅថ្ងៃ ទី

[6] នៅថ្ងៃ ទី៨ កុម្ភៈ ឆ្នាំ ១៩៧១ លោក លន់ នល់ មាន ជម្ងឺ hémiplégie ហើយ នៅថ្ងៃ ទី ១៣ កុម្ភៈ លោក ចាកចេញ ពី ស្រុកខ្មែរ ទៅ ព្យាបាល រោគ នៅ កោះ Honolulu នៃ សហរដ្ឋអាមេរិក។ លោក វិលត្រឡប់មក ស្រុកខ្មែរ វិញ នៅថ្ងៃ ទី១២ មេសា ហើយ នៅថ្ងៃ ទី២០ មេសា លោក សូម លាលែង ពី តំណែង នាយករដ្ឋមន្ត្រី។

# ម្ដេចក៏ សាធារណរដ្ឋខ្មែរ ?

## ការប្រទាញប្រទង់គ្នា

១១ ឧសភា លោក យ៉ែម សំបូ ត្រូវបាន ជាប់ឆ្នោត ជា ប្រធាន រដ្ឋសភា ជំនួស លោក អ៊ិន តាំ។

នៅថ្ងៃ ទី ៨ កញ្ញា ឆ្នាំ ១៩៧១ មាន ការបង្កើត គណកម្មាធិការ យោធា សំរាប់ ធ្វើសហការ ជាមួយ គណកម្មការ ទូលាយ ដើម្បី តាក់តែង រដ្ឋធម្មនុញ្ញ នៃ រដ្ឋសភា។ នៅថ្ងៃ ទី២៣ កញ្ញា លោក អ៊ិន តាំ លាលែងពីតំណែង ឧបនាយករដ្ឋមន្ត្រី។

នៅថ្ងៃ ទី១៨ តុលា ឆ្នាំ ១៩៧១ រដ្ឋសភា ប្រែក្លាយ ជា រដ្ឋសភា ធម្មនុញ្ញ, ហើយ នៅក្នុង រយះពេល ធ្វើសេចក្ដីព្រាងច្បាប់នោះ, រដ្ឋាភិបាល ចេញ បញ្ញាតិ យក អំណាច នីតិបញ្ញាតិ មកកាន់កាប់ ជា បណ្ដោះអាសន្ន ហើយ ប្រកាស ដាក់ ប្រទេស ឋិត នៅ ភាពអាសន្ន។ នៅថ្ងៃ ទី២០ តុលា មាន ការបះបោរ នៃ និស្សិត មួយពួក និង ព្រះសង្ឃ មួយក្រុម ទាមទារ ឱ្យលោក លន់ នល់ ទទួល តំណែង ជា ប្រមុខរដ្ឋ[7]។ នៅថ្ងៃ ទី២១ តុលា លោក ឡុង ប៊ូរ៉េត រដ្ឋមន្ត្រី ក្រសួង ព័ត៌មាន ធ្វើសេចក្ដី កែតម្រូវ ពី ពាក្យ ចចាមអារ៉ាម ថា ការចេញបញ្ញាតិ យក អំណាច នីតិបញ្ញត្តិ មកកាន់កាប់ និង ការប្រកាស ដាក់ ប្រទេស ក្នុង ភាពអាសន្ន របស់ រដ្ឋាភិបាល មិនមែន ជា រដ្ឋប្រហារនោះឡើយ។ នៅថ្ងៃ ទី ២៥ តុលា លោក ឡុង ប៊ូរ៉េត ចេញ សេចក្ដីថ្លែងការណ៍មួយទៀត

[7] សម្ដេចសង្ឃ គណៈ មហានិកាយ ប្រកាស ប្រឆាំងនឹង ការប៉ុនប៉ង យក ព្រះសង្ឃ ចូលធ្វើ សកម្មភាព នយោបាយ។

# ម្តេចក៏ សោកនាដកម្មខ្មែរ ?

## ការប្រែតាញប្រែនច់គ្នា

ថា លោក លន់ នល់ អាចយល់ព្រម ធ្វើ ជា ប្រមុខរដ្ឋ ឬ ប្រធានាធិបតី លុះត្រាតែ ស្រុកខ្មែរ ផ្គត់ផ្គង់ ដោយ រដ្ឋធម្មនុញ្ញ ពេញ ច្បាប់។

នៅថ្ងៃ ទី៨ វិច្ឆិកា ១៩៧១ លោក អ៊ិន តាំ បានជាប់ឆ្នោត ជា ប្រធាន រដ្ឋសភា ធម្មនុញ្ញ។

នៅថ្ងៃ ទី១២ វិច្ឆិកា ឆ្នាំ ១៩៧១ លោក លន់ នល់ ទទួចសូមឱ្យ រដ្ឋសភា ធម្មនុញ្ញ ប្រញាប់ បញ្ចប់ ការតាក់តែង រដ្ឋធម្មនុញ្ញ។ នៅថ្ងៃ ទី១៥ វិច្ឆិកា គណកម្មការ ចំរុះ បញ្ចប់ កិច្ចប្រជុំ នៃ ការ តាក់តែង រដ្ឋធម្មនុញ្ញ រួច ផ្តល់ ការងារ នៃ គំរោង រដ្ឋធម្មនុញ្ញ ជូន ទៅ រដ្ឋសភា ធម្មនុញ្ញ។

នៅខែ កុម្ភៈ ឆ្នាំ ១៩៧២ រដ្ឋសភា ធម្មនុញ្ញ ចាប់ ពិភាក្សា គំរោង នៃ រដ្ឋធម្មនុញ្ញ។ នៅថ្ងៃ ទី២៥ កុម្ភៈ លោក កែវ អាន ព្រឹទ្ធ សាស្ត្រាចារ្យ នៃ មហាវិទ្យាល័យ និតិសាស្ត្រ រិះគន់ ទ្រង់ សិរិមតៈ ថា ប្រព្រឹត្ត អំពើ ពុករលួយ។ ដូច្នេះ លោក បានត្រូវ ដកហូត ពី មុខដំណែង ដែល នាំឱ្យ មជ្ឈដ្ឋាន និស្សិត មាន បដិយៈ (mécontentement)។

នៅថ្ងៃ ទី១០ មីនា ឆ្នាំ ១៩៧២ មាន បាតុកម្ម នៃ និស្សិត និង សិស្ស សាលា វិទ្យាល័យ ប្រឆាំងនឹង ទ្រង់ សិរិមតៈ ជា នាយករដ្ឋ មន្ត្រី ប្រតិភូ។ នៅថ្ងៃ ទី១០ មីនា លោក ចេង ហេង ប្រកាស

# ម្តេចក៏ សាធារណរដ្ឋខ្មែរ ?

## ការប្រដាញប្រដច់គ្នា

បញ្ចប់ បេសកកម្ម រដ្ឋសភា ផម្មនុញ្ញ ហើយ លាលែង ពី ដំណែង ប្រមុខរដ្ឋ។ នៅថ្ងៃ ទី១២ មីនា ទ្រង់ សិរិមតៈ លាលែង ពី តំណែង នាយករដ្ឋមន្ត្រី ប្រតិភូ។ នៅថ្ងៃ ទី១៣ មីនា លោក លន់ នល់ ប្រកាស ដោយ ខ្លួនឯង ឡើងកាន់ ដំណែង ជា ប្រធានាធិបតី។

នៅថ្ងៃ ទី៩ មេសា ឆ្នាំ ១៩៧២ រដ្ឋាភិបាល ផ្សាយ ជា សាធារណៈ គំរោង រដ្ឋធម្មនុញ្ញ។ នៅថ្ងៃ ទី៣០ មេសា ធ្វើប្រជាមតិ រដ្ឋធម្មនុញ្ញ។

នៅថ្ងៃ ទី៤ មិថុនា លោក លន់ នល់ ជាប់ឆ្នោត ជា ប្រធានាធិបតី នៃ សាធារណរដ្ឋខ្មែរ។ នៅពេល បោះឆ្នោតនោះ មាន បេក្ខជន បីនាក់: លោក លន់ នល់, អ៊ិន តាំ និង កែវ អាន។ ជ័យជំនះ របស់ លោក លន់ នល់ ត្រូវបាន លោក កែវ អាន ចោទប្រកាន់ ថា មាន ការប្រទ្បំ សន្លឹកឆ្នោត, ចំពោះលោក អ្នក ដែល ឈ្នះ គឺ ជា រូបលោក មិនមែន លោក លន់ នល់ នោះទេ។

### នៅក្រោយ ឆាកល្ខោន នៃ រដ្ឋសភាធម្មនុញ្ញ

យើងឃើញថា តាំងពី បង្កើត សាធារណរដ្ឋខ្មែរ នៅថ្ងៃ ទី៩ តុលា ឆ្នាំ ១៩៧០ មកដល់ ថ្ងៃ ប្រកាស កំណើត រដ្ឋធម្មនុញ្ញ នៅថ្ងៃ ទី ៩ មេសា ឆ្នាំ ១៩៧២ វា មាន រយៈពេល ដ៏យូរអង្វែងមួយ ដែល នាំឱ្យមាន ការចោទ ជា សំនួរ ថា វា មាន អ្វី កើតឡើងនៅ

# ម្ដេចក៏ សោធនារណរដ្ឋខ្មែរ?

## ការប្រទាញប្រទង់គ្នា

ក្រោយ ឆាកល្ខោន (coulisse) នៃ រដ្ឋសភា ជម្ពូទុញ្ញ? ត្រូវ រំឭកឡើង ថា រដ្ឋសភា ជម្ពូទុញ្ញ ជា អតីត រដ្ឋសភា កើតឡើង នៅឆ្នាំ ១៩៦៦ ដែល មាន កេរ៍ឈ្មោះ ថា ជា រដ្ឋសភា តំណាង ប្រជាពលរដ្ឋខ្មែរ ពិតប្រាកដ ហើយ ពួក តំណាងរាស្ត្រ សុទ្ធតែ ជា វរជន ដែល ប្រជាពលរដ្ឋខ្មែរ ជ្រើសរើស ដោយ ផ្ទាល់ ទៅតាម ការស្រឡាញ់ពិត របស់ខ្លួន ហើយ រដ្ឋសភានោះឯង ជា អ្នកបោះឆ្នោត ទំលាក់ សម្ដេច សីហនុ ពីមុខតំណែង។ ដូច្នេះ រដ្ឋសភានោះ ទោះបី ក្លាយ ជា រដ្ឋសភា ជម្ពូទុញ្ញ តែពួក អ្នកតំណាងរាស្ត្រ នៅ ដដែល ហើយ នៅ តែ មាន មោទនភាព ថា ខ្លួន ជា តំណាងរាស្ត្រឯករាជ្យ មិននៅ ក្រោម អំណាច នីតិប្រតិបត្តិនោះឡើយ។ ដូច្នេះ ម្នាក់ៗ ទាមទារ ចំណែក នៃ បដិការគុណ (reconnaissance) នៅក្នុង ព្រឹត្តិការណ៍ ថ្ងៃ ទី១៨ មីនា ឆ្នាំ ១៩៧០។ ប៉ុន្តែ នៅក្នុង យុទ្ធភូមិ នយោបាយ ពួក តំណាងរាស្ត្រ ទាំងនោះ ពុំអាច រក្សា ឯកភាព របស់ ពួកខ្លួន បាននោះឡើយ នៅ ចំពោះមុខ ការប្រទាញប្រទង់គ្នា មាន នៅក្នុង អំណាច នីតិប្រតិបត្តិ ដែលនាំឱ្យ ពួក តំណាងរាស្ត្រទាំងនោះ បែក ជា ក្រុម ទៅតាម មុខគំនិត នៃ ការប្រយុទ្ធ មតិ របស់ខ្លួន រៀងៗខ្លួន។ ក្រុម លោក ចេង ហេង, អតីត ប្រធាន រដ្ឋសភា និង ជា ប្រមុខរដ្ឋ ជំនួស សម្ដេច សីហនុ ដែល ជា ក្រុម ភាគច្រើន មាន និន្នាការ គាំទ្រ ទ្រង់ សិរិមតៈ។ ក្រុម លោក អ៊ឹង ម៉ឹង ដែល ទាមទារ ជា អ្នកជំនាញច្បាប់ ហើយ ស្នើ គំរោង រដ្ឋធម្មនុញ្ញថ្មី

# ម្តេចក៏ សាធារណរដ្ឋខ្មែរ ?

## ការប្រទាញប្រទង់គ្នា

តាំង ពីដើមដំបូង បន្ទាប់ ពី បង្កើត សាធារណរដ្ឋខ្មែរ។ ក្រុម ទី៣ ជា ក្រុម របស់លោក អ៊ិន តាំ ដែល ទាមទារ ថា ខ្លួន ជា អ្នកសកម្ម ជាងគេ នៅក្នុង ព្រឹត្តិការណ៍ ថ្ងៃ ទី១៨ មីនា។ ក្រុម ទី៤ ជា ក្រុម តាំងខ្លួន ជា អ្នកសាធារណរដ្ឋ ពិតប្រាកដ ហើយ គាំទ្រសកម្មភាព ពួក សម្ព័ន្ធភាព លោក ហង្ស ធុន ហាក់-លន់ ណុន-កេង វ៉ាន់ សាក់ ហើយនាំគ្នាគាំទ្រ ការបង្កើត នៃ គណកម្មាធិការ សាធារណរដ្ឋ ដោយលោក លន់ ណុន ក្រៅ ក្របខណ្ឌ រដ្ឋសភា នៅថ្ងៃ ទី ៧ មីនា ឆ្នាំ ១៩៧១ ដើម្បី ការពារ របបសាធារណរដ្ឋ។ តាម ការពិត គណកម្មាធិការនោះ គឺ បង្កើតឡើង ដើម្បីតាមពិនិត្យ សកម្មភាព ទ្រង់ សិរិមតៈ នៅពេល ដែល លោកលន់ នល់ ទៅ ព្យាបាល ជម្ងឺ នៅ HONOLULU។ ពួក ទី៥ ជា ពួកតំណាងរាស្ត្រ ដែល មិនចូល ក្រុមណាមួយ ហើយ តាំងខ្លួន ជាជនឯករាជ្យ ដូចជា លោក ឌុក រ៉ាស៊ុំ[8] ជា អាថ៌។

យើងឃើញថា រដ្ឋសភា បែកខ្ញែកខ្ចី ជា ចំណែកតូចៗ ដែលនាំឱ្យបាត់ ភាពឯករាជ្យ និង អាព្យាក្រឹតភាព ជា ពិសេស បាត់អំណាច នៃ ស្ថាប័នជាតិចមមួយ នៅចំពោះមុខ ការប្រទាញ

[8] លោក ឌុក រ៉ាស៊ី លោក ជាតំណាងរាស្ត្រផង ហើយ ជា ចៅងហ្វាង នៃ ទស្សនាវដ្តីរដ្ឋ ជា ភាសាបារាំង ឈ្មោះ « réalités cambodgiennes » តាមរយៈ ទស្សនាវដ្តីនោះ លោក តែងតែ សរសេរ អត្ថបទ រិះគន់ រដ្ឋាភិបាល ត្រង់ៗ ដែលនាំឱ្យ រដ្ឋាភិបាល ដកតំណែងលោក នៅខែ កញ្ញា ឆ្នាំ ១៩៧១ បន្ទាប់ ពី លោក សរសេរ ប្រឆាំងនឹង សំណើរ របស់លោក លន់ នល់ ឱ្យទាហាន អាចបោះឆ្នោតបាន។

# ម្ដេចក៏ សាធារណរដ្ឋខ្មែរ ?

## ការប្រទាញប្រទង់គ្នា

ប្រទង់ នៅក្នុង ដំណើរ នៃ ការបង្កើត នៃ របប សាធារណរដ្ឋ។ រឿងមួយ គួរលើកយកមកជំរាប អំពី កល្បិច នយោបាយមួយ រវាង ក្រុមនិមួយៗ នៅពេល ធ្វើការបោះឆ្នោត ជ្រើសរើស ប្រធានរដ្ឋសភា ថម្មនុញ្ញ។ នៅពេល បង្កើត រដ្ឋាភិបាលថ្មី នៅ ថ្ងៃ ទី ៦ ឧសភា ឆ្នាំ ១៩៧១ ដែល មាន លោក អ៊ិន តាំ ជា ឧបនាយករដ្ឋមន្ត្រី, លោកឪពុកខ្ញុំ មិនចូលរួម ដោយ មាន សំណើរ ពី ក្រុមលោក ចេង ហេង, ទ្រង់ សិរិមតៈ និង លោក លន់ នល់ ឱ្យ រៀបចំខ្លួន ឈរឈ្មោះ ជា បេក្ខជន នៃ ប្រធាន រដ្ឋ សភា ថម្មនុញ្ញ ព្រោះ លោកឪពុកខ្ញុំ គាត់ ក៏ជា តំណាងរាស្ត្រ ម្នាក់ដែរ។ តែ លោក អ៊ិន តាំ លោក ត្រូវបាន ក្រុមលោក ស្នើ ឱ្យ ឈរ ជាមេក្ខជនដែរ តម្រូវ ឱ្យលោក លាលែង តំណែង ឧបនាយករដ្ឋមន្ត្រី។ បេក្ខភាព របស់លោក អ៊ិន តាំ ដែល មិន បានគ្រងទុក នាំឱ្យ មាន ការគិតគូរ រវាង ក្រុមនីមួយ នៅក្នុង រដ្ឋសភា ដើម្បី យកឈ្នះចាញ់គ្នា នៅពេលបោះឆ្នោត។ ពួក ដែល គាំទ្រ លោក ឪពុកខ្ញុំ មាន ក្រុម លោក ចេក ហេង, ពួក តំណាងរាស្ត្រ ឯករាជ្យ និង តំណាងរាស្ត្រ មួយចំនួន នៅក្នុង ក្រុម លោក អ៊ឹង ម៉ឹង។ ទោះបី បេក្ខជន លោក ឪពុកខ្ញុំ មាន ការគាំទ្រ ពី សំណាក់ លោក លន់ នល់ ក៏ដោយ, តែ លោក លន់ ណុន ជា ប្អូន របស់លោក លន់ នល់ និង លោក ហង្ស ធុន ហាក់ នាំគ្នា ធ្វើសកម្មភាព ដោយ សម្ងាត់ ប្រឆាំងនឹង បេក្ខភាព របស់គាត់ ព្រោះពួកនោះ គេ យល់ឃើញ ថា បើ លោក ឪពុកខ្ញុំ

# ម្ដេចក៏ សាធារណរដ្ឋខ្មែរ ?

## ការប្រជាញប្រជល់គ្នា

ជាប់ឆ្នោត ជា ប្រធាន រដ្ឋសភា ធម្មនុញ្ញ ច្បាស់ ជា រដ្ឋសភា ធ្លាក់ ទៅក្នុងដៃ របស់ ទ្រង់ សិរិមតៈ ដ្បិត ពួកគេ ទុក លោកឪពុកខ្ញុំ ជា ដៃ នយោបាយ របស់ ទ្រង់ សិរិមតៈ។ ឧបាយ នោះ ទទួល បាន លទ្ធផល ដូច គោលបំណងមែន ព្រោះ លោក អ៊ិន តាំ លោក បាន ឈ្នះ លោក ឪពុកខ្ញុំ ពីរ សន្លឹកឆ្នោត។ យើង ឃើញថា ពួក លោក លន់ ណុន និង ហង្ស ធុន ហាក់ ដើម្បី ប្រឆាំងនឹង ទ្រង់ សិរិមតៈ សុខចិត្ត ជ្រើសរើស លោក អ៊ិន តាំ ជា ប្រធាន រដ្ឋសភា ដែល ជា សត្រូវ នយោបាយនឹង លោក លន់ នល់ ជំនួសនឹង លោក ឪពុកខ្ញុំ ដែល ជា មនុស្ស ជំនិតម្នាក់ នឹង លោក លន់ នល់។ ការចាញ់នោះ ចំពោះលោក ឪពុកខ្ញុំ គាត់ គ្មាន ការតូចចិត្តអ្វីនោះឡើយ ព្រោះ នយជន ត្រូវ ទទួល យក លទ្ធផល យ៉ាងណាក្ដី នៃ ការបោះឆ្នោត, ប៉ុន្ដែ លោក ម៉ៃ ទៅលើ សម្មានភាព (sincérité) របស់លោក លន់ នល់ មកលើរូប លោក ដែល ជា មិត្តនយោបាយ តាំងពីយូរយារ មកហើយ។

រដ្ឋសភា ធម្មនុញ្ញ បើកស្រម័យជុំ នៅ ខែ តុលា ឆ្នាំ ១៩៧១ ដើម្បី តាក់តែង រដ្ឋធម្មនុញ្ញ។ ការពិភាក្សា មាន រយៈពេល ដ៏យូរ អង្វែង មិនមែន មានន័យ ថា រដ្ឋសភានោះ មាន គំនិត ប្រទាំងនឹង របប សាធារណរដ្ឋនោះឡើយ តែ ជា ទម្លាប់ នៃ ពួក អ្នកតាក់តែងច្បាប់ តែងតែ ស្វែងរក គុណភាព នៃ ច្បាប់ ដូច្នេះ វា នាំ ឱ្យមាន ការពិភាក្សា ដោយ ភាពល្អិតល្អន់ និង

# ម្ដេចក៏ សាធារណរដ្ឋខ្មែរ ?

## ការប្រទាញប្រទង់គ្នា

ជម្រៅ ដូចយ៉ាង ជម្រើស រវាង របប ប្រធានាធិបតីនិយម, របប សភានិយម ឬ របប ចំរុះ ដែល នៅពេល ពិភាក្សានោះ វា មាន សម្លេងមតិ ស្មើរ តែស្មើគ្នា។ ការអូសប្រលាយ នៃ ការបកស្រាយ អំពី គុណសម្បត្តិ នៃ របប នីមួយៗ នៅពេលពេលនោះ នាំឱ្យលោក លន់ នល់ បាត់អំណត់ ហើយ នៅ ថ្ងៃ ទី១២ វិច្ឆិការ លោក សូមឱ្យ រដ្ឋសភា ធម្មនុញ្ញ បញ្ចប់ ការតាក់តែងច្បាប់ ដើម្បី យក រដ្ឋមនុញ្ញនោះ ធ្វើប្រជាមតិ ដែល រដ្ឋាភិបាល គ្រង ធ្វើ នៅថ្ងៃ ទី ១៥ កុម្ភៈ ឆ្នាំ ១៩៧២។ តែ នៅខែ កុម្ភៈនោះ រដ្ឋសភា ធម្មនុញ្ញ មាន ទំនាស់ នឹង ការស្នើ របស់ រដ្ឋាភិបាល ឱ្យមាន កំរិត នៃ ចំនួន នៃ គណបក្ស នយោបាយ ដែលនាំ ឱ្យ ខកខាន ធ្វើ ប្រជាមតិ ព្រោះ ការតាក់តែង រដ្ឋធម្មនុញ្ញ វា មិន អាចបញ្ចប់ ទាន់ពេលវេលា។ កំហកនោះ នាំឱ្យ ក្រុម លោក លន់ ណុន និង ហង្ស ធុន ហាក់ ចោទប្រកាន់ ថា ជា សមយុទ្ធ របស់ ក្រុម សិរិមតៈ និង ចេង ហេង។ ដូច្នេះ នៅថ្ងៃ ទី១០ មីនា ក្រុម លន់ ណុន និង ហង្ស ធុន ហាក់ ញុះញង់ ក្រុម និស្សិត មួយក្រុម ជា ពិសេស សិស្សានុសិស្ស នៃ វិទ្យាល័យ ឱ្យបះបោរ ប្រឆាំងនឹង សិរិមតៈ។ មកដល់ ចំណុចនេះ គួរលើកយក សកម្មភាព របស់ លោក លន់ ណុន ដែល ជា ប្អូន របស់ លោក លន់ នល់ មក ពិនិត្យមើល ដើម្បី បំភ្លឺ បន្ថែម អំពី ការប្រទាញប្រទង់គ្នា។

# ស្ដេចកឺ សាធារណរដ្ឋខ្មែរ ?

## ការប្រទាញប្រទង់គ្នា

### ហង្ស ធុន ហាក់ - លន់ ណុន

ដើម្បី ប្រឆាំងនឹង ទ្រង់ សិរិមតៈ លោក លន់ ណុន[9] ស្វែងរក សម្ពន្ធមិត្ត របស់គាត់។ នៅពេលនោះដែរ ក៏មាន ក្រុម លោក ហង្ស ធុន ហាក់[10] ដែល ជា ក្រុម អតីត ខ្មែរ ឥស្សរៈ ក៏កំពុង

---

[9] លោក លន់ ណុន (១៩២០-១៩៧៥) ជា ប្អូនពៅ របស់លោក លន់ លន់, លោក ធ្លាប់បានមករៀន នៅ ស្រុកបារាំង ក្នុង មុខវិជ្ជា ឧក្រិដ្ឋវិទ្យា, បន្ទាប់មក បានចូលធ្វើជា ស្នងការ ប៉ូលិស, ក្រោយមក ចូល សិក្សា ជា សិស្សនាយទាហាន ជំនាន់ ទី១៣ បន្ទាប់ ចូលបំរើ កងទ័ព នៅក្នុង កង អាវុធហត្ថ។ នៅដើម ព្រឹត្តិការណ៍ ថ្ងៃ ទី១៨ មីនា ឆ្នាំ ១៩៧០ លោក មាន ឋានន្តរស័ក្តិយោធា ជា អនុសេនីយឯក។ នៅសម័យ សាធារណរដ្ឋខ្មែរ លោក ឡើង ឋានន្តរស័ក្តិ ជា ឧត្តមសេនីយត្រី ជា មេបញ្ជាការ កងពល តូច លេខ១៣។ លោក ធ្លាប់ ជា សមាជិក នៃ រដ្ឋាភិបាល ដឹកនាំដោយ លោក ហង្ស ធុន ហាក់ ជា រដ្ឋមន្ត្រី ទទួលបំទុក កំណែន ទូទៅ និង ផ្គត់ផ្គង់។ នៅថ្ងៃ ទី១៧ មេសា លោក មាន បំណង ធ្វើ រដ្ឋប្រហារ ដោយប្រើ ទាហាន ស្ម័គ្រនឹងលោក ចំនួន ប្រមាណ ២០០ នាក់ ពាក់ ឯកសណ្ឋាន ពណ៌ខ្មៅ ដឹកនាំ ដោយ មេ ឈ្មោះ ហែម កេត ដារា លាតពល នៅទីក្រុង ភ្នំពេញ ស្រែក បញ្ជា ឱ្យទាហាន ដាក់អាវុធ ដើម្បី ទទួល ទាហាន ខ្មែរ ក្រហម នៅក្នុង ក្របខណ្ឌ ចរចា ដើម្បី បញ្ឈប់ សង្គ្រាម តែ នៅពេល ពួក ខ្មែរក្រហម ចូលមកកាន់កាប់ ទីក្រុង ភ្នំពេញ ពួកនោះ យក ពួក លោក លន់ ណុន ទៅសម្លាប់ចោល រីឯ លន់ ណុន វិញ ត្រូវបាន មនុស្ស មួយក្រុម វាយ យ៉ាងឃោរឃៅបំផុត នៅទីសាធារណៈ រហូតដល់ស្លាប់។

[10] ហង្ស ធុន ហាក់ (១៩២៦-១៩៧៥) : សិក្សា វិជ្ជាល្ខោន នៅ សាលា Sarah Bernard នៅ ទីក្រុង ប៉ារីស ហើយ ត្រឡប់វិលចូលស្រុកខ្មែរនៅឆ្នាំ ១៩៥១។ លោក រត់ចូលព្រៃ តាម លោក ស៊ឹង ង៉ុក ថាញ់ ដើម្បី បង្កើត ចលនា ទាមទារឯករាជ្យ ពី បារាំង។ នៅក្នុង ចលនានោះ លោក ជា អ្នកផ្សាយ តាមវិទ្យុ ជា ការឃោសនា នយោបាយ។ ក្រោយពីស្រុក ទទួល បាន ឯករាជ្យ លោក ត្រឡប់មកភ្នំពេញ ហើយបានធ្វើការ ជា សាស្ត្រាចារ្យ នៅ វិទ្យាល័យ ស៊ីសុវត្ថិ។ បន្ទាប់មក បានទទួលតំណែង ជា ចាងហ្វាង ក្រុមល្ខោនជាតិ នៅភ្នំពេញ ហើយ ក្រោយមក ត្រូវបានតែងតាំង ជា សាកលវិទ្យាការ នៃ សាកលវិទ្យាល័យ វិចិត្តសិល្បៈ ពីឆ្នាំ ១៩៦៦ ដល់ ឆ្នាំ ១៩៧០។ នៅក្នុង សាធារណរដ្ឋខ្មែរ លោក ធ្លាប់ធ្វើ ជា រដ្ឋមន្ត្រី ក្រសួង

# ម្ដេចក៏ សាធារណរដ្ឋខ្មែរ ?

## ការប្រណាញប្រជន់គ្នា

ស្វែងរក អានុភាព នយោបាយ របស់ខ្លួននោះដែរ។ ជំនែង[11] របស់លោក លន់ ណុន គឺ ដើម្បី ការពារ អំណាច បង របស់ លោក ដែល មាន ជម្ងឺ ប្រចាំកាយ នាំឱ្យគាត់ រំគាយ កម្លាំង កាយ និង បញ្ញា។ នៅចំពោះ ស្ថានការនោះ លោក លន់ ណុន ភ័យបារម្ភ ខ្លាច ទ្រង់ សិរិមតៈ ឆ្លៀតឱកាស ហួងយកអំណាច, ដូច្នេះ គាត់ បង្កើត «គណម្ចាធិការ សាធារណរដ្ឋ» ក្រៅ ស្ថាប័នជាតិ ដើម្បី ពាំង ការប៉ុនប៉ង របស់ទ្រង់ សិរិមតៈ ដែល កំពុង កាន់អំណាច ជំនួស លោក លន់ នល់។ ដើមឡើយ នៅពេល ប្រជុំ មាន សមាជិក គណរដ្ឋមន្ត្រី ចូលរួម ដូចជា លោក ហង្ស ធុន ហាក់, អ៊ុង ស៊ិម និង ឆន សុខុម, ក៏មានផង ពួក នាយ ទាហាន, បញ្ញវន្ត, ភិក្ខុ មួយចំនួន និង ភ្នំភឿន[12] របស់លោក លន់ ណុន។ បន្ទាប់មក ភិក្ខុ ខៀវ ជុំ ត្រូវបានជ្រើសរើស ជា ប្រធាន បណ្ដោះអាសន្ន នៃ គណកម្មាធិការនោះ។ គណប្រតិភូ មួយ ដឹកនាំដោយ ភិក្ខុ ខៀវ ជុំ និង លោក ប៉ុនចន្ទ ម៉ុល, វរសេនីយទោ ថាច់ ជា និង លោក សន ថាត[13] ជា សាមាជិក សូម

---

អភិវឌ្ឍន៍សហគមន៍ ក្រោយមក ទទួលតំណែង ជា រដ្ឋមន្ត្រី ទី១ នៅថ្ងៃ ទី ១៩៧២ ដល់ថ្ងៃ ទី ១៧ មេសា ឆ្នាំ ១៩៧៣។ លោក បាន និពន្ធ រឿង ល្ខោន មួយចំនួន និង បកប្រែ រឿងល្ខោនមស្ទឹមប្រទេស ដែរ។ លោក បានបាត់បង់ជីវិត នៅពេលដែល ពួកខ្មែរក្រហម ឈ្នះសង្គ្រាម នៅឆ្នាំ ១៩៧៥។

[11] ជំនែង : ការជែង។

[12] ភ្នំភឿន : ពួកក្លើ, គូកន។

[13] សន ថាត ជា អតីត អ្នកដឹកនាំ និស្សិត។

# ម្ដេចក៏ សាធារណរដ្ឋខ្មែរ ?

## ការប្រទាញប្រទង់គ្នា

ចូលជួប លោក ចេង ហេង ជា ប្រមុខរដ្ឋ និង ទ្រង់ សិរិមតៈ ជា នាយករដ្ឋមន្ត្រី ប្រតិភូ ដើម្បី បង្ហាញ និវេទន៍ (manifeste) របស់ គណកម្មាធិការ ដែល នៅក្នុងនោះ មាន ចំណុចសំខាន់បីគឺ: បញ្ចប់ របបរាជានិយម, ពង្រឹង សាធារណរដ្ឋខ្មែរ និង អប់រំ ប្រជាពលរដ្ឋ ដើម្បី ឱ្យក្លាយ ជា កម្លាំង សាធារណរដ្ឋ។ ស្របនឹង គណកម្មាធិការនោះដែរ លោក លន់ ណុន បង្កើត អង្គការ ក្រៅ ស្ថាប័នជាតិ មួយទៀត ឈ្មោះ « គណកម្មាធិការ នៃ ការសំរបសំរួល ដើម្បី ការពារជាតិ » គណកម្មាធិការ នេះ សំដែង ជា សាធារណៈ នូវ គោលការណ៍ របស់ខ្លួន គឺ សំរាប់ ពាំង នៅចំពោះមុខ គ្រប់ ការប៉ុនប៉ង បង្កើតឡើងវិញ នៃ របប រាជានិយម។ គណកម្មាធិការ ទាំងពីរនោះ ដូចបាន ជំរាបរួចមកហើយ គឺ បង្កើត នៅក្រៅ ស្ថាប័នរដ្ឋ ហើយ ពីដំបូង ពួក ដែល ចូលរួម នឹកស្មាន ថា មាន ការអនុញ្ញាត ពី លោក លន់ នល់ តែ ក្រោយបន្តិចមក ក៏ដឹងថា វា ជា ការផ្ដួតផ្ដើម របស់លោក លន់ ណុន និង កេង វ៉ាន់ សាក់ ក៏នាំគ្នា ដកខ្លួន ចេញពី អង្គការនោះ។ ប៉ុន្ដែ លោក ហង្ស ធុន ហាក់ នៅតែ បន្ត ធ្វើសកម្មភាព យ៉ាងសកម្ម ដោយ ប្រើ កម្លាំង នៃ ឥទ្ធិពល របស់លោក លន់ ណុន ដើម្បី ការវិលត្រឡប់ លោក ស៊ឹង ង៉ុក ថាញ់ មកក្នុង ឆាកនយោបាយជាតិ នៅក្នុង គំរោង យក នរជននោះ ជំនួយ លោក លន់ នល់ ជា មនុស្ស ជម្ងឺ និង បណ្ដេញ ទ្រង់ សិរិមតៈ ពី អំណាច។ ក្រុម លោក ហង្ស ធុន ហាក់ ហៅ ថា ក្រុម ‹ភ្នំដងរែក› មាន លោក កេង វ៉ា

# ម្តេចក៏ សាធារណរដ្ឋខ្មែរ ?

## ការប្រណាញប្រជែងគ្នា

ន់ សាក់[14] ជា ទីប្រឹក្សា ស្រមោល ឬមិនចេញមុខ (conseiller de l'ombre) ក្នុង ឋានៈ ជា អ្នកទ្រឹស្តី នយោបាយ មាន ជំនឿជាក់ច្បាស់ ថា

14 ក្រោយមក ក្រុមលោក ហង្ស ធុន ហាក់ បាន បញ្ជូន លោក កេង វ៉ាន់ សាក់ ទៅធ្វើ ជា ឯកអគ្គរដ្ឋទូត ប្រចាំ នៅ អង្គការ UNESCO ដែលមាន ទីស្តីការ នៅ ស្រុកបារាំង ដើម្បី ធ្វើជា អ្នកទំនាក់ទំនង សម្ងាត់ ជា មួយ ពួក ខ្មែរក្រហម និង ខ្មែរយៀកមិញ។ លោក ធ្លាប់ ជួប ជាសម្ងាត់ ជាមួយ លោក អៀង សារី។ រឿងនេះ លោក កេង វ៉ាន់ សាក់ ខ្លួនឯង ធ្លាប់ និយាយប្រាប់ខ្ញុំ និង មិត្តភក្តិ របស់ខ្ញុំ មួយចំនួន ដែល តែងតែ ទៅជួប សំណេះសំណាល នយោបាយ ជាមួយគាត់ នៅទសវត្សរ៍ ៩០។ លោក លន់ នល់ កោតសរសើរ ចំណេះចេះដឹង របស់លោក កេង វ៉ាន់សាក់ ក្នុង វិស័យ វប្បធម៌ខ្មែរ ជា ពិសេស អំពើ វប្បធម៌ ‹ខ្មែរ-មន› ដែលលោក យកមក ធ្វើជា មូលដ្ឋាន នៃ ទ្រឹស្តី របស់ សាធារណរដ្ឋខ្មែរ។ ត្រូវដឹងថា វា មាន ការពិបាកនឹងឡោម គំនិត នយោបាយ របស់លោកកេង វ៉ាន់ សាក់ : ជា មនុស្ស ឆ្វេងនិយម ? មិនពិតនោះឡើយ ព្រោះគាត់ ជា មនុស្ស ស្រឡាញ់ ភាសុកភាព (confort) សម្ភារៈ ច្រើនណាស់។ ត្រង់ចំណុចនេះឯង ដែល អៀង សារី ចោទប្រកាន់ ដល់ រូបលោក។ នៅ ទសវត្សរ៍ ៥០ លោក ស្ថិត នៅក្នុង ក្រុម អ្នកប្រជាធិបតី ជឿនលឿន ដែលជា ក្រុម ដណ្តើម អំណាចបាន នៅក្នុង គណបក្ស ប្រជាធិបតេយ្យ នៅឆ្នាំ ១៩៥៥។ ជ័យជំនះឯង ដែល ក្រុមនោះ អាច ធ្វើឱ្យ លោក ស៊ឹង ង៉ុកថាញ់ ខ្ទាតចេញពីគណបក្ស។ តែ លោក កេង វ៉ាន់ សាក់ ច្បាស់ ជា អ្នកប្រឆាំងនឹង សម្តេច សីហនុ ហើយ នៅ សម័យ សាធារណរដ្ឋខ្មែរ លោកស្អប់ទ្រង់ សិរិមតៈ ណាស់។ ការស្អប់ ពួក ស្តេច មិនមែន ដោយសារលោក ជា អ្នកប្រឆាំងនឹង រាជានិយម នោះឡើយ តែ លោក ស្អប់ ឪពុកបង្កើត របស់លោក ដែល ជា ស្តេច ហើយមិនទទួលស្គាល់លោកជាកូន។ ដូច្នេះ សម្ព័ន្ធភាព របស់លោក ជាមួយ ក្រុម ភ្នំដងរ៉ែក និង លន់ ណុនជា ចំណង កើតចេញពី កំហឹងផ្ទាល់ខ្លួន ច្រើនជាង គោលចំណង់ នយោបាយ។ លោក មិនបាន គាំទ្រ សាធារណរដ្ឋខ្មែរ ពេញលេញនោះឡើយ ព្រោះ លោក យល់ឃើញ ថា វា គ្រាន់ តែ ជា របប នៅក្នុង ដំណើរការ នៃ ដំណាក់ការ នៃ បដិវត្តន៍។ ពិតណាស់ហើយ លោក មិនចង់ឱ្យពួក ខ្មែរក្រហម មាន ជ័យជំនះ ព្រោះ លទ្ធិកុម្មុយនិស្ត មិនមែន ជា ជំរើស របស់លោកនោះឡើយ។ លោក និង ប៉ុល ពត ធ្លាប់មាន ទំនាក់ទំនង ជិតស្និតនឹងគ្នា ព្រោះ លោក នេះឯង ដែល បាន ផ្តល់យោបល់ឱ្យ

# ម្ដេចក៏ សាធារណរដ្ឋខ្មែរ ?

## ការប្រទាញប្រទង់គ្នា

អាច មាន ដំណោះស្រាយ នយោបាយ ជា មួយខ្មែរ ម្ខាងទៀត គឺ ពួក ខ្មែរក្រហម និង ខ្មែរវៀតមិញ ដែល កំពុង ជួយ យួន កុម្មុយនិស្ត វាយ កងទ័ពខ្មែរ ព្រោះ ពួកខ្លួន មាន សន្ថិដ្ឋមិត្ត[15] ជាប្រវត្តិសាស្ត្រ ជាមួយ ពួកទាំងនោះ។ មួយវិញទៀត ក្រុម លោក ហង្ស ធុន ហាក់ មានទំនាក់ទំនង សម្ងាត់ ជាមួយ ស្ថាន ទូត សូវៀត ហើយ រៀបចំខ្លួននឹង ជំនួស លោក លន់ នល់ ដែល គេ ទុក ជា មនុស្ស ពិការ បន្ទាប់ពី លោក មាន រោគ ស្លាប់មួយ ជំហៀងខ្លួន (hémiplégie)។ ដូច្នេះ ឧបសគ្គ ដែល ត្រូវ ឆ្លងកាន់ គឺ ទ្រង់ សិរិមតៈ ព្រោះ ជា សត្រូវ នៃ អំណាច និង វណ្ណៈផង។ ដើម្បី ដកចេញ ឧបសគ្គនេះ ក្រុម លោក ហង្ស ធុន ហាក់ ត្រូវការ មនុស្ស ដែល មាន ស្នាម សន្ទិដ្ឋិក[16] នៅក្នុង ប្រវត្តិសាស្ត្រ នយោបាយ គឺ លោក ស៊ឹង ង៉ុក ថាញ់ ដែល ជា អតីត មគ្គនាយក[17] សំខាន់ម្នាក់ នៃ ចលនា ខ្មែរឥស្សរៈ និង ខ្មែរសេរី ប្រឆាំងនឹង សម្ដេច សីហនុ។ លោក ស៊ឹង ង៉ុក ថាញ់ បាន លោក លន់ លន់ តែងតាំង ជា ទីប្រឹក្សា នៃ រដ្ឋាភិបាល តាំងពីថ្ងៃ ទី ១៤ សីហា ឆ្នាំ ១៩៧០, ដូច្នេះ លោក ចាប់ផ្ដើម មាន សកម្មភាព នយោបាយ ជាថ្មី នៅស្រុកខ្មែរ តាំពីពេលនោះមក តែ លោក

---

ប៉ុល ពត រត់ចូលព្រៃ ហើយ លោក នោះដែរ ដែល ជា អ្នកជូនដំណើរ ប៉ុល ពត រត់ចូលព្រៃ រហូតដល់ ខេត្ត កំពុងចាម។

15 សន្ថិដ្ឋមិត្ត : មិត្តចាស់ ដែលនៅរក្សា ការរាប់អានគ្នា ទៅវិញទៅមក។

16 សន្ទិដ្ឋិក : ដានដែលអាចមើលឃើញ។

17 មគ្គនាយក : អ្នកដឹកនាំ, អ្នកនាំផ្លូវ។

# ម្ដេចក៏ សាធារណរដ្ឋខ្មែរ ?

## ការប្រណាញប្រនច់គ្នា

មិនមាន ប្រជាប្រិយភាព ខ្លាំងក្លា នោះឡើយ, នយជនខ្មែរ ភាគច្រើន មិនសូវមាន វិស្សាសភាព[18] ចំពោះលោក ព្រោះលោក បានទៅរស់នៅ នៅ ស្រុកយួន ខាងត្បូង (កម្ពុជាក្រោម) ជាង មួយទសវត្សរ៍។ ចំណែក យុវជន និង ប្រជាពលរដ្ឋខ្មែរ វិញ មិន សូវ ស្គាល់លោកផង ដូច្នេះ ការវិលត្រឡប់របស់លោក វា គ្មាន បន្ថែមតម្លៃ នយោបាយ ជាក់ស្ដែង ដល់ ជាតិខ្មែរ នោះឡើយ។ រីឯ នៅក្នុង កងទ័ព វិញ លោក មាន ឥទ្ធិពល ស្ដួចស្ដើងណាស់ ទៅលើ ពួកនាយទាហាន ជាន់ខ្ពស់ ព្រោះ ពួកនោះ តែងតែទុក លោកជា សត្រូវ នៅក្នុង អារម្មណ៍ របស់ខ្លួន ព្រោះលោក ធ្លាប់ ជា មារអារុជ នឹងខ្លួន។ តែ លោក លន់ នល់ ជា មនុស្ស ជម្ងឺ ចាប់ផ្ដើម បាត់ សេចក្ដីឈ្លាសវៃ ដែលនាំឱ្យលោក លន់ ណុន ជា ប្អូន មាន ឥទ្ធិពល មកលើរូបលោក ព្រោះលោក ទុក ប្អូនលោក ជា ភ្នែក ច្រមុះ និង ត្រចៀក របស់លោក។ ឥទ្ធិពលនោះឯង ដែល ក្រុមលោក ហង្ស ធុន ហាក់ ខ្ញាំ ឱកាសបាន ដើម្បី បញ្ចូល លោក ស៊ឹង ង៉ុក ថាញ់ ចូលទៅជិតលោក លន់ នល់ ព្រោះ ពួក គេ កៀងគរគាត់ ថា ល្បែង លទ្ធិប្រជាធិបតេយ្យ នៅក្នុង បរិបទ សង្គ្រាម វា ជា គ្រោះថ្នាក់ ដល់ សាធារណរដ្ឋខ្មែរ, ដូច្នេះ លោក លន់ នល់ ត្រូវការចាំបាច់ មាន មនុស្សខ្លាំងម្នាក់ ដែល ជា និមិត្តរូប ពិតប្រាកដ នៃ របប សាធារណរដ្ឋ ដើម្បី ចាក់ឫស

18 វិស្សាសភាព : សេចក្ដីទុកចិត្ត។

# ស្តេចភី សាធារណរដ្ឋខ្មែរ ?

## ការប្រទាញប្រទង់គ្នា

សំណង់ នៃ សាធារណរដ្ឋខ្មែរ ព្រោះ ទ្រង់ សិរិមតៈ ជា ស្ដេច និង ក្អែល នៃ របប សក្ដិភូមិ មិនអាច ដើរតួឯក ជា អ្នកកសាង សាធារណរដ្ឋខ្មែរ បានជាដាច់ខាត។ ជឿលើ គុណធម៌នេះ លោក លន់ នល់ ជម្រុញឱ្យ លោក ចេង ហេង លាលែង ពី តំណែង ប្រមុខរដ្ឋ នៅថ្ងៃ ទី១០ មីនា ឆ្នាំ ១៩៧២ ហើយ លោក យក ដំណែងនោះ មកកាន់កាប់ ក្នុង ឋានៈ ជា ប្រធានាធិបតី។ ព្រឹត្តិការណ៍ចម្បងនោះ តម្រូវឱ្យ ទ្រង់ សិរិមតៈ លាលែង ពី តំណែង នាយករដ្ឋមន្ត្រី ប្រតិភូ នៅថ្ងៃ ទី១២ មីនា, បន្ទាប់មក ទ្រង់ ប្រកាស ដកខ្លួនចេញ ពី ឆាកនយោបាយ។ នៅថ្ងៃ ទី២១ មីនា លោក ស៊ឹង ង៉ុក ថាញ់ ត្រូវបាន លោក លន់ នល់ តែងតាំង ជា រដ្ឋមន្ត្រីទី១។ នៅថ្ងៃ ទី២៣ លោក កុយ ប៊ុច ប្រធាន និស្សិត មហាវិទ្យាល័យ នីតិសាស្ត្រ និង វិទ្យាសេដ្ឋកិច្ច ប្រមាថ លោក លន់ នល់ នៅក្នុង កម្មវិធីទូរទស្សន៍ នៃ ការ ពន្យល់ ច្បាប់រដ្ឋធម្មនុញ្ញ ថា ជា ស្ដេចយក្ស កំណាច ឬ ជនផ្ដាច់ការ។ ការប្រមាថនោះ បាននាំឱ្យ លោក ស៊ឹង ង៉ុក ថាញ់ បញ្ជា ឱ្យចាប់ខ្លួនលោក កុយ ប៊ុច។ នរជននោះ រត់ ទៅពួន នៅក្នុង មហាវិទ្យាល័យ របស់គាត់ ដោយ មាន និស្សិត ជា ច្រើន អប អងគាត់ ផ្ញើ ជា អ្នកការពារគាត់ នៅតាម របង នៃ មហាវិទ្យាល័យ។ នៅថ្ងៃ ទី២៦ មេសា លោក ស៊ឹង ង៉ុក ថាញ់ បញ្ជា ឱ្យបិទ ទ្វារ មហាវិទ្យាល័យ ទាំងអស់។ នៅវេលាព្រឹកថ្ងៃ ទី២៧ មេសា កងអាវុធហត្ថ ទទួល បញ្ជា ពី ថ្នាក់លើ ឱ្យ សង្កុញ ចូលចាប់

## ម្ដេចក៏ សាធារណរដ្ឋខ្មែរ ?

### ការប្រណាញ់ប្រណង់គ្នា

លោក កុយ ប៊ុច តាម ច្រកទ្វារធំ នៃ មហាវិទ្យាល័យ។ តាំងតែ ពីព្រលឹមស្រាង កងអារុធហត្ថ បាន បាន សាកល្បង វាយ សម្រុកចូល តែ ត្រូវ ក្រុម និស្សិត រុញច្រាន មិនឱ្យចូល។ ការរុញ ច្រានគ្នា ទៅវិញទៅមក អស់មួយកប្ប[19] ស្រាប់តែ នៅពេល ម៉ោង ១០ ព្រឹក មាន ឮសួរបាញ់កាំភ្លើង ពីរបីគ្រាប់ ដែលនាំ បញ្ឈប់ ការរុញច្រានគ្នានោះទៅ។ តែ ពួក និស្សិត មួយក្រុម បានស្រែក ថា មាន មនុស្សរបួស និង ស្លាប់ ព្រោះ មាន ការ បាញ់ប្រហារ ពី កងអារុធហត្ថ។ ស្អែកឡើង កាសែត ‹ នគរធំ › សរសេរ ថា លោក ឧប គឹម អួន[20], វរសេនីយទោ នៃ កងអារុធ

[19] កប្ប (កាប់) ន. : កាលដែលតាំងនៅយូរអង្វែង។

[20] លោក ឧប គឹម អួន ជា ពូ របស់ខ្ញុំ, ប្អូនប្រុសទី៣ របស់លោក ឪពុក ខ្ញុំ។ លោក ជា សិស្សនាយទាហាន ជំនាន់ទី១៣ (ជំនាន់ របស់លោក លន់ ណុន) បន្ទាប់មក បានទៅសិក្សា នៅស្រុកបារាំង ក្នុង សាលា នៃ ការ អនុវត្ត របស់កងទ័ពជើងគោក (école d’application à Coëtquidan) នៅ ស្រុកបារាំង ចំនួន ២ឆ្នាំ។ ត្រឡប់មកស្រុកខ្មែរវិញ លោក ត្រូវរាជ ការយោធា ឱ្យទៅកាន់បញ្ជាការ នៅ ស្រុក អាចម៍រមាស់ បន្ទាប់មក ទៅធ្វើការ នៅ មជ្ឈមណ្ឌល សម្ភារៈយោធា នៅ ស្រុក លង្វែក នៅក្រោម បញ្ជាការ របស់លោក វរសេនីយឯក ហួ ត្រួក (សិស្សនាយទាហាន ជំនាន់ ទី១)។ នៅឆ្នាំ ១៩៧១ លោក បានទៅសិក្សា នៅ ប្រទេស ចិនតៃវ៉ាន់ នៅ សាលា សង្គ្រាម នយោបាយ។ នៅក្នុង ប្រតិបត្តិការសឹក ចេនឡា ទី១ លោក ត្រូវតែងតាំង ជា មេបញ្ជាការ នៃ កងឃោសនា នយោបាយ។ នៅឆ្នាំ ១៩៧២ លោក ត្រូវបានតែងតាំង ជា ចាងហ្វាង នៃ មជ្ឈមណ្ឌល មជ្ឈមណ្ឌល បណ្ដុះបណ្ដាល អភិវឌ្ឍន៍ នាយទាហាន កងអារុធហត្ថ។ នៅ ពេល លោក អ៊ិន តាំ ឡើងធ្វើ ជា នាយករដ្ឋមន្ត្រី លោក ត្រូវ លោក អ៊ិន តាំ តែងតាំង ជា អ្នករៀបចំ បង្កើត កងតម្រួត សាធារណរដ្ឋខ្មែរ។ លោក មាន របួស នៅពេល ពួកខ្មែរក្រហម បាញ់ គ្រាប់ រ៉ូកែត ១២២ មកក្នុង ទីក្រុងភ្នំពេញ។ លោក ទទួលមរណៈភាព នៅសម័យ ខ្មែរក្រហម។

## ម្ដេចក៏ សាធារណរដ្ឋខ្មែរ ?

### ការប្រឆាញប្រឆន់គ្នា

ហត្ថ, ជា អ្នកបញ្ជាឱ្យបាញ់។ នៅទីនេះ ខ្ញុំ លើក អង្គហេតុ មក ជំរាបៈ នៅថ្ងៃ ដែលកើតហេតុ លោក ឧត្តមសេនីយត្រី ជា គឹម អេង, មេបញ្ជាការ កងអាវុធហត្ថជាតិ បាន បញ្ជា ឱ្យ ពូ របស់ ខ្ញុំ ទៅមើល ស្ថានការ នៅមុខ មហាវិទ្យាល័យ នីតិសាស្ត្រ, នៅ ពេលដែល រថយន្ត Jeep របស់គាត់ទៅដល់ទីកន្លែងនោះ មាន ស្នូរផ្ទុះភ្លាម, ថៃដន្យនោះឯង ដែល នាំឱ្យមាន ការចោទ ប្រកាន់ថា ពូ របស់ខ្ញុំ ជា អ្នកបញ្ជា ឱ្យបាញ់។ ត្រូវដឹងថា ស្នូរ នោះទៀត វា មិនមែន ជា ស្នូរកាំភ្លើងនោះឡើយ វា ជា ស្នូរ ផ្ទុះ គ្រាប់បែកផ្សែង ដែល កងអាវុធហត្ថ បោក បំបែកជួរ ក្រុម និស្សិត ដែល គះគា ពួកខ្លួន។ ការបោក គ្រាប់បែកផ្សែង នោះ ទៀត មិនមែន ពូ របស់ខ្ញុំ ជា អ្នកបញ្ជាផងដែរ ព្រោះ នៅពេល នោះ គាត់ មិនមែន ជា មេបញ្ជាការ នៃ កងអាវុធហត្ថ នៅទី កន្លែងនោះឡើយ ដូច្នេះ គាត់ គ្មាន អាជ្ញាសឹក អាច បញ្ជាកង ឯកភាពនោះ បានទេ ព្រោះកងនោះ គេមាន មេបញ្ជាការ ផ្ទាល់ របស់គេ។ ការពិត នៅពេលនោះ គ្មាន មនុស្ស ស្លាប់ អ្វី នោះឡើយ មាន តែ អ្នករបួសស្រាល ពីរបីនាក់ តែប៉ុណ្ណោះ។

តែ ការចោទប្រកាន់ គ្មាន ព័ស្តុតាង របស់ កាសែត ‹ នគរធំ › ត្រូវបាន ពួកលោក នល់ ណុន គេ ទាញយក ជា ប្រយោជន៍ នយោបាយ ដោយ ដាក់កំហុស ទៅលើ ទ្រង់ សិរិមតៈ ថា ជា នៅ

# ម្ដេចក៏ សាធារណរដ្ឋខ្មែរ ?

## ការប្រជាញប្រជង់គ្នា

ពីក្រោយរឿងនោះ ក្នុង បំណង ធ្វើអនត្ថការ[21] ដល់ សកម្មភាព របស់លោក ស៊ឹង ង៉ុក ថាញ់ ព្រោះ លោក វរសេនីយទោ ឧប គីម អួន ជា ប្អូន លោក ឧប គីម អាង ជា មនុស្សជំនិតនឹងទ្រង់ សិរិមតៈ ដែល ជា អ្នកបញ្ជា ឱ្យបាញ់ ពួក និស្សិត ដើម្បី ទម្លាក់ កំហុស មកលើ រដ្ឋាភិបាល។ តែ ល្បិចកលនេះ វា គ្មាន នរណាម្នាក់ អាចជឿបាន ទាំងនៅក្នុង មជ្ឈដ្ឋាន នយោបាយ, សមាគម នៃ និស្សិត និង បញ្ជាការដ្ឋានជាន់ខ្ពស់ នៃ យោធា ដ្បិត វា មិនមែន ជា ចារឹត របស់ទ្រង់ សិរិមតៈ ហើយ បញ្ជាការ បែប នោះ វា មិនអាចកើតមានបាន ព្រោះ វា ខុស ពី ក្បួនវិន័យយោធា។ តែ សំនួរមួយ សួរ ថា ហេតុអ្វី ក៏ លោក ឧត្តមសេនីយ ជា គឹម អេង បញ្ជា ឱ្យ លោក វរសេនីយទោ ឧប គីម អួន ទៅ ស្ទង់ មើល ស្ថានការ នៅ មហាវិទ្យាល័យ នីតិសាស្ត្រ ហើយ ពេលលោក ទៅដល់កន្លែងនោះភ្លាម ក៏មាន ផ្ទុះគ្រាប់បែងផ្សែង ជា ច្រើន គ្រាប់ ? សួរថា ជា ចៃដន្យ ឬ ជា ការរៀបចំទុកជាមុន ?

យើងឃើញ ថា ក្នុង រយៈពេល តែមួយខែ តែប៉ុណ្ណោះ លោក ស៊ឹង ង៉ុក ថាញ់ ជា រដ្ឋមន្ត្រី ទី១ បានជ្រើសរើស ជម្លោះ ជាមួយ យុវជន ដែលនាំ ឱ្យ មតិមហាជន មាន ការសង្ស័យ ទៅលើ សមត្ថភាព ផ្សះផ្សាជាតិ របស់លោក ជាអ្នកចាស់ទុំម្នាក់ ដើម្បី ស្វែងរក ការស្រុះស្រួលជាតិ នៅក្នុង ការពង្រឹង សាធារណរដ្ឋខ្មែរ, ស្វ

[21] ធ្វើអនត្ថការ : ធ្វើឱ្យអន្តរាយដោយចេតនា។

# ម្ដេចក៏ សាធារណរដ្ឋខ្មែរ ?

## ការប្រណាញ់ប្រជែងគ្នា

ម្បី លោក លន់ នល់ ក៏មាន មន្ទិល ក្នុងរឿងនេះដែរ។ តែ ភាពចាំបាច់ របស់ លន់ នល់ គឺ ឱ្យលោក ក្លាយ ជា ប្រធានាធិបតីពេញសិទ្ធិ តាមទំនាន់ចិត្ត តម្រូវឱ្យលោក ពឹងផ្អែកទាំងស្រុងទៅលើ ក្រុម លោក ហង់ ធុន ហាក់ តាមរយៈ (via) លោក ស៊ឹង ង៉ុក ថាញ់[22] នោះឯង ដើម្បី ជំរុញ ដំណើរការ នៃ កំណើត រដ្ឋធម្មនុញ្ញ នៃ សាធារណរដ្ឋខ្មែរ ឱ្យបាន លឿនបំផុត ដើម្បី រៀបចំការបោះឆ្នោត ជ្រើសរើស ប្រធានាធិបតី។ សំនួរ សួរថា ចំណង់របស់លោក លន់ នល់ ជា ចំណង់ ធ្វើ ជា ប្រធានាធិបតី ឬ ជាចំណង់ ពង្រឹង សាធារណរដ្ឋខ្មែរ ? ចំពោះលោក ស៊ឹង ង៉ុក ថាញ់ ដែល ក្រុមលោក ហង្ស ធុន ហាក់ មាន គំរោងការ កន្ទោង[23] យករូបលោក មក ជំនួសលោក លន់ នល់ កាត់មុខទ្រង់ សិរិមតៈ, នៅក្នុង ករណី ដែល លោក លន់ នល់ លែងមាន សុពលភាព អាចបន្ត ដឹកនាំ សាធារណរដ្ឋខ្មែរ, វា មិនដូច សេចក្ដីប្រាថ្នា នោះទេ ព្រោះ នៅពេលដែល នរជននោះ កាត់អំណាចបានតែមួយខែ ស្រាប់តែ គាត់ បង្ករហេតុ ជាមួយ យុវជន។ ជាការពិត ចាប់ពី ជម្លោះនោះមក លោក ស៊ឹង ង៉ុក ថាញ់ លោក

---

[22] ត្រូវដឹងថា លោក ស៊ឹង ង៉ុក ថាញ់ ជា រដ្ឋមន្ត្រី ទី១ តែងតាំង ដោយ លោក លន់ នល់ មិនមែន ជា នាយករដ្ឋមន្ត្រី ទទួល សេចក្ដីទុកចិត្ត ពី រដ្ឋសភានោះឡើយ ព្រោះ នៅពេលនោះ អំណាច នីតិបញ្ញាតិ ត្រូវបាន លោក លន់ នល់ យកមកកាន់កាប់ ក្នុង ឋានៈ ជា ប្រធានាធិបតី ប្រកាសដោយខ្លួនឯង ហើយ រដ្ឋសភា ប្រែក្លាយ ជា រដ្ឋសភា ធម្មនុញ្ញ គ្មាន អំណាច នីតិបញ្ញាតិនោះឡើយ។

[23] កន្ទោង : ន.គុ. ដែលជាធំ, ដែលជាមេខ្លោង, ម្ដាយ។

# ម្ដេចក៏ សាធារណរដ្ឋខ្មែរ ?

## ការប្រឆាំងប្រឆាំងគ្នា

គ្រាន់តែ បន្ត ធ្វើភារកិច្ចជម្មតា នៃ រដ្ឋាភិបាល រហូត ដល់ ការ បង្កើត គ្រប់ ស្ថាប័ន នៃ សាធារណរដ្ឋខ្មែរ និង ជា និមិត្តរូប នៃ ប្រតិសិរិមតៈ (anti-Siri matak)។ លោក លាលែងពីតំណែង រដ្ឋមន្ត្រី ទី ១ នៅថ្ងៃ ទី១៤ តុលា ឆ្នាំ ១៩៧២ រួចវិលត្រឡប់ ទៅរស់នៅ កម្ពុជាក្រោមវិញ។ ការលាលែងនោះ លោក លើកយក ហេតុផល ថា បេសកកម្ម របស់លោក បានបំពេញ ចប់សព្វគ្រប់អស់ហើយ៖ សាធារណរដ្ឋខ្មែរ មាន ស្ថាប័ន ពេញលេញ និង ត្រឹមត្រូវ តាម ច្បាប់ រដ្ឋធម្មនុញ្ញ គឺ ប្រធានាធិបតី (ថ្ងៃ ទី៤ មិថុនា ឆ្នាំ ១៩៧២), រដ្ឋសភា (ថ្ងៃ ទី៣ កញ្ញា ឆ្នាំ ១៩៧២) និង ព្រឹទ្ធសភា (ថ្ងៃ ទី១៧ កញ្ញា ឆ្នាំ ១៩៧២)ជ្រើសតាំង ដោយ ការបោះឆ្នោត ស្រប តាម ច្បាប់ រដ្ឋធម្មនុញ្ញ ដែល ជា ច្បាប់កំពូល ទទួលស្គាល់ ជាផ្លូវការ តាម ការធ្វើប្រជាមតិនៅថ្ងៃ ទី ៣០ មេសា ឆ្នាំ ១៩៧២ ហើយ កៅអីតំណាង នៃ សាធារណរដ្ឋខ្មែរ ត្រូវបាន មហាសន្និបាត នៃ អង្គការ សហប្រជាជាតិ បោះឆ្នោត ទទួលស្គាល់ ជាផ្លូវការ នៅថ្ងៃ ទី១២ តុលា ឆ្នាំ ១៩៧២ ដោយមាន ប្រទេស ១៣២ បោះឆ្នោត ទទួលស្គាល់ និង ១១ ប្រទេស បោះឆ្នោត ប្រឆាំង មាន ប្រទេស Albanie, Algérie, Chine, Congo ; Cuba ; Irak ; Mauritanie, Roumanie, Sénégal, Série និង Yougoslavie។ នៅថ្ងៃ ទី២៨ តុលា គណកម្មការ សំរាប់ ពិនិត្យ ការសម្រេច នៃ មហាសន្និបាត នៃ អ.ស.ប. យល់ព្រម ដោយ

# ម្តេចក៏ សាធារណរដ្ឋខ្មែរ ?

## ការប្រណាញប្រណង់គ្នា

មាន ចំនួន ៦២ ប្រទេស គាំទ្រ, ១៧ ប្រទេស ប្រឆាំង និង ១៧ ប្រទេសទៀត អនុបវាទ។

លោក ស៊ឹង ង៉ុក ថាញ់ ធ្លាប់ឡើង កាន់អំណាច ពីរដង នៅ ស្រុកខ្មែរ, ទី១ តែងតាំងដោយ ហ្លួង សីហនុ នៅថ្ងៃ ទី១៦ សីហា ឆ្នាំ ១៩៤៥ ជា រដ្ឋមន្ត្រី ទី១ និង រដ្ឋមន្ត្រី ក្រសួង ការបរទេស ដល់ថ្ងៃ ទី ១៥ តុលា ដែលជាថ្ងៃ ដែល បារាំង ចាប់ លោក បញ្ជូន ទៅ ឃុំឃាំង នៅ ស្រុកបារាំង នៅពេល ដែល បារាំង គេ វិលត្រឡប់ មក ត្រួតត្រា ស្រុកខ្មែរវិញ, លើក ទី២ តែងតាំង ជា រដ្ឋមន្ត្រី ទី ១ និង រដ្ឋមន្ត្រីក្រសួង ការបរទេស ដោយ លោក លន់ នល់ នៅ ថ្ងៃ ទី២១ មីនា ឆ្នាំ ១៩៧២ ដល់ ថ្ងៃ ទី១៤ តុលា ថ្ងៃ ដែល លោក លាលែង ពី តំណែង។ រយៈពេល ដ៏ខ្លី ទាំងពីរលើកនោះ វា មិន បាន បង្ហាញ ស្នាដៃ របស់លោក ជា អ្នកដឹកនាំជាតិ ស្មើនឹង កេរ៉ណ្ដោះលោក ជា អ្នកតស៊ូ ដើម្បី ឯករាជ្យជាតិ។ ការសុខចិត្ត ទទួល តំណែង ជា រដ្ឋមន្ត្រី ទី១ នៅ ឆ្នាំ ១៩៧២ នៅក្នុង កលល្បិច នៃ ការដណ្ដើម អំណាច វា មិនបាន លើក តម្លៃ របស់គាត់ ជា រដ្ឋបុរស, ផ្ទុយទៅវិញ វា នាំឱ្យគាត់ មាន រូបភាព ប្រឡាំ (image floue) ជា មនុស្សឱកាសនិយម។ ការបញ្ជា ឱ្យចាប់ លោក កុយ ប៊ុច, មេដឹកនាំ និស្សិត, វា ប្រហក (enfoncer dans) គាត់ ទៅក្នុង កេរ៉ណ្ដោះ ជា អ្នកប្រឆាំងនឹង សេរីភាព ឬ ជា សត្រូវនឹងយុវជន។ ក្នុងរយៈពេលដ៏ខ្លី នៅក្នុង អំណាច ជាអ្នកបម្រើអំណាច ដើម្បី

# ម្ដេចក៏ សាធារណរដ្ឋខ្មែរ ?

## ការប្រនាញប្រនប់គ្នា

គ្រាន់តែ ប្រឆាំងនឹង ទ្រង់ សិរិមតៈ វា មិនបាន បង្ហាញ រូបភាពគាត់ ជា អ្នកសាធារណរដ្ឋ បង្រួបបង្រួមជាតិ នៅក្នុងសង្គមខ្មែរ ប្រេះឆា។ សួរថា តើ ជា ធម្មជាតិ របស់គាត់ ឬ គាត់ចាញ់បោក ក្រុម លោក ហង្ស ធុន ហាក់-លន់ ណុន-កេង វ៉ាន់សាក់ ?

### ទ្រង់ សិរិមតៈ

ទ្រង់ សិរិមតៈ ទ្រង់ គ្មានក្រុមនោះទេ, ទ្រង់ ចែករំលែក អំណាចជាមួយលោក លន់ នល់ តាំងពី ការបង្កើត នៃ រាជរដ្ឋាភិបាលស្រោចស្រង់ មកម្លេះ។ ការប្រកាស សាធារណរដ្ឋខ្មែរ ទោះបី ទ្រង់ជា ស្ដេច ក៏ វា គ្មាន ទុក្ខកន្លែង[24] នោះឡើយ។ ផ្ទុយទៅវិញ នៅថ្ងៃ ទី ១៤ ឧសភា ឆ្នាំ ១៩៧០ ទ្រង់ ប្រកាស ក្នុង សំបុត្រ ផ្សាយជា សាធារណៈ ថា ទ្រង់ បោះបង់ចោល រាជងារ របស់ទ្រង់។ កាយវិការនោះ ធ្វើឡើង ដើម្បី រួមដំណើរ ជាមួយ ការបង្កើតសាធារណរដ្ឋខ្មែរ ព្រោះ ទ្រង់ យល់ឃើញ ថា រាជងារនោះ វា វិសមិត[25] នឹង តម្លៃ សាធារណរដ្ឋ និង ជា ចម្លើយ ចំពោះ សម្ដេចសីហនុ ដែល ព្រះអង្គ ប្រកាស បង្កើត រណសិរ្ស បង្រួបបង្រួមរួមជាតិខ្មែរ (FUNK) និង រាជរដ្ឋាភិបាល បង្រួបបង្រួមជាតិខ្មែរ (GRUNK) នៅ ទីក្រុងប៉េកាំង ដើម្បី វាយប្រហារ កងទ័ពជាតិខ្មែរ ដែល

---

24 កន្លែង គុ. : សង្រេកចិត្ត, មានទុក្ខធ្ងន់អន្ទះអន្ទេងក្នុងចិត្ត។
25 វិសមិត : មិនត្រូវគ្នា។

# ម្ដេចក៏ សាធារណរដ្ឋខ្មែរ ?

## ការប្រទាញប្រទង់គ្នា

ព្រះអង្គ ធ្លាប់ជា អ្នកបង្កើត។ ចម្លើយនោះ គឺ មាន គោលបំណង ចង់ បង្ហាញ ថា ទំនាស់ នយោបាយ រវាង ទ្រង់ នឹង សម្ដេច សីហនុ មិនមាន លក្ខណៈ ជា កុលវិបត្តិ[26] នោះឡើយ។ ដូច្នេះ គោលការណ៍ នៃ ការប្រទាញប្រទង់គ្នា នៅក្នុង ការបង្កើត សាធារណរដ្ឋខ្មែរ វា មិនទាក់ទងអ្វីនឹង ទ្រង់នោះទេ តែសត្រូវ នយោបាយ របស់ទ្រង់ គេ យក បុគ្គល សិរិមតៈ ជានិមិត្តរូប នៃ មនុស្ស ជាបដិបក្ខ ក្នុង សញ្ជ័យ[27] (conquête) នៃអំណាច ដែល វា ផ្ទុយនឹង សង្គតិ[28] រវាង លោក លន់ នល់ និងទ្រង់ សិរិមតៈ ក្នុង ការកសាង របប សាធារណរដ្ឋ។ នៅត្រង់ចំណុចនេះឯង ដែល អាចទុកជា ទស្សនៈ ផ្ទុយគ្នា រវាង ក្រុមលោក ហង្ស ធុន ហាក់ និង ទ្រង់ សិរិមតៈ ដែល ក្រុមលោកហង្ស ធុន ហាក់ ជា អ្នកបង្កជម្លោះ។ អ្នកទីមួយ ប្រើប្រាសសាធារណរដ្ឋខ្មែរ ជា មធ្យោបាយ សំរាប់ ដណ្ដើម អំណាច, រីឯទ្រង់ សិរិមតៈ វិញ ទ្រង់ ត្រកង សាធារណរដ្ឋខ្មែរ នៅក្នុង អភិក្រម នៃ ប្រជាធិបតេយ្យូបនីយកម្ម (démocratisation) នៃ ជីវិតនយោបាយ ជាតិខ្មែរ ដែល សម្ដេច សីហនុ ព្រះអង្គ បំផ្លាញចោល នៅ ទស្សវត្ស ៥០។ នៅថ្ងៃ ទី១២ មីនា ឆ្នាំ ១៩៧២ ទ្រង់សិរិមតៈ លាលែង ពី តំណែង នាយករដ្ឋមន្ត្រី ប្រតិភូ ហើយ

26 កុលវិបត្តិ : វិបត្តិត្រកូល។
27 សញ្ជ័យ : ការប្រយុទ្ធដណ្ដើម។
28 សង្គតិ ន. : ការរួមគំនិតគ្នា, សេចក្ដីស្មោះស្មើទៅវិញទៅមករកគ្នា។

# ម្ដេចក៏ សោកនាដកម្មខ្មែរ ?

## ការប្រទាញប្រទង់គ្នា

បន្ទាប់មក ប្រកាស តាម វិទ្យុជាតិ នៅថ្ងៃ ទី១៦ មីនា ថា ទ្រង់ ដកខ្លួនចេញ ពី ជីវិត នយោបាយ។ ហេតុផល នៃ ការសម្រេចចិត្តនេះ គឺ ទ្រង់ សង្កេតឃើញថា លោក លន់ នល់ ដែល ជា ដៃគូ នយោបាយ របស់ទ្រង់ កំពុង រសាត់ តាមខ្យល់អំណាច នៅក្នុង ការប្រទាញប្រទង់ ជារញ្ជួះ[29] នៃ ក្រុមនយោបាយ លោភា។

**និទានខ្លីៗ** (anecdote)

រឿងខ្លីមួយ គួរលើកមក បង្ហាញ អំពី មិត្តភាព ដ៏បរិសុទ្ធ របស់ទ្រង់ សិរិមត: ចំពោះ លោក លន់ នល់ បន្ទាប់ពី បរាជ័យ នៃ ប្រតិបត្តិការសឹក ចេនឡា ទី២ នៅខែ ធ្នូ ឆ្នាំ ១៩៧១, ឯកអគ្គរដ្ឋទូត អាមេរិកាំង លោក Emory Swank ផ្ញើរ ទូរលេខពីរ ទៅ ក្រសួង ការបរទេសអាមេរិកាំង ក្នុងនោះ លោក បានរិះគន់ ដោយផ្ទាល់ អំពី យុទ្ធសាស្ត្រ ខ្ជីខ្ជា នៃ ប្រតិបត្តិការសឹង ចេនឡា ទី២។ ចាប់ពីពេលនោះមក លោក លន់ នល់ និង លោក E. Swank មាន ទំនាក់ទំនង រកាំរកូសនឹងគ្នា រហូត លោក ជំរាបដល់ ក្រសួង ការបរទេស អាមេរិកាំង អំពី ការសង្ស័យ របស់លោក លើ សមត្ថភាព របស់លោក លន់ នល់ បន្ត ដឹកនាំ ស្រុកខ្មែរ។ សហរដ្ឋអាមេរិក ក៏ប្រញាប់ បញ្ជូន ក្រុមវេជ្ជសាស្ត្រ មក ពិនិត្យ សុខភាព របស់លោក លន់ នល់។ នៅក្នុង របាយការណ៍ វេជ្ជសាស្ត្រ បានបង្ហាញថា លោក លន់ នល់ មាន ជម្ងឺ ស្ពុះសរសៃ

---

[29] រញ្ជួះ : គុ. ដែលមិនមានផល។

# ម្ដេចក៏ សាធារណរដ្ឋខ្មែរ ?

## ការប្រឆាញប្រឆង់គ្នា

ឈាម នៅក្នុង លលាដ៍ក្បាល ច្រើនកន្លែង។ តាម ទស្សនៈ វេជ្ជសាស្ត្រ យ៉ាងយូរ ពី ៦ ទៅ ៨ ខែ រោគ ស្ទះសរសៃឈាម របស់ លោក លន់ នល់ នឹង អាច លាប់ឡើងវិញ ដែល ជួនកាល ក៏នាំ ឱ្យគាត់ បាត់ ស្មេរភាព នៃ បញ្ញា និង សុពល ក្លាយ ជា អ្នក ពិការ ជួនកាល ក៏គាត់ ត្រូវបាត់បង់ជីវិត តែម្ដង។ នៅក្នុង បរិបទនេះឯង ដែល លោក E. Swank បាន សូមជួប ទ្រង់ សិរិមតៈ។ នៅក្នុង ជំនួបនោះ មាន លោកឪពុក របស់ខ្ញុំដែរ, លោក Swank និយាយត្រង់ៗថា លោក លន់ នល់ ជា មនុស្ស ពិការ ដូច្នេះ ច្បាស់ ជា លោក បាត់ សេចក្ដីឈ្លាសវៃ សំរាប់ ដឹកនាំ កិច្ចការរដ្ឋ និង យោធា, ខ្ញុំ សួរ ទ្រង់ ថា ៈ តើ វា អាចមាន លទ្ធភាព ដែល អាចឱ្យគាត់ លាលែង ពី តំណែង ឬ ប្ដូរ លោក បាន ដែរ ឬទេ ដើម្បី ផលប្រយោជន៏ ជាតិខ្មែរ ? សហរដ្ឋអាមេរិក គាំទ្រដល់ទ្រង់ បើទ្រង់ អាចមាន លទ្ធភាព ធ្វើបាន ទៅតាម គ្រប់មធ្យោបាយ ដែលទ្រង់មាន។ ទ្រង់ សិរិមតៈ ឆ្លើយតបវិញ ជា ពាក្យប្រើប្រដូច (métaphore) ថា : លោក លន់ នល់ និង ខ្ញុំ ជា គូដៃរួមផ្លូវ ជាមួយគ្នា, យើង ដាំបាយ សំរាប់ បរិភោគ ជាមួយគ្នា តែ ឥឡូវ បាយនោះ វា ខ្លោច ដោយសារ គេ មើលឃើញថា លោក លន់ នល់ គាត់ខ្វះ ការប្រុងប្រយ័ត្ន ដោយ គាត់ មាន ជម្ងឺ, តែ នៅក្នុង កលៈទេសៈនេះ យើង កំពុង ឃ្លានបាយណាស់ ហើយ បាយខ្លោចនោះ យើង អាចបរិភោគ មួយពេលបាន គ្រាន់តែ វា មិនឆ្ងាញ់, ដូច្នេះ ប្ដូរ លោក លន់ នល់ នៅក្នុង ស្ថានភាព

## ម្ដេចក៏ សាធារណរដ្ឋខ្មែរ ?

### ការប្រណាញប្រណង់គ្នា

បែបនេះ វា ប្រៀបដូចជា ត្រូវខ្ញុំ ចោលបាយខ្លោចនោះ ដែល យើង កំពុងត្រូវការបរិភោគ ដើម្បី សម្រាល សេចក្ដីឃ្លាន របស់ យើងសិន, ថ្ងៃស្អែក យើង នឹងដាំបាយ ដោយ ប្រុងប្រយ័ត្ន ជាមួយលោក លន់ នល់។ ទ្រង់ សិរិមតៈ និយាយបន្ថែមថា ៈ ប៉ុន្តែ កិច្ចការមួយ ដែល លោក អាចជួយ ប្រជាជាតិខ្មែរបាន គឺ លោក ជួយ កៀងគរ (convaincre) លោក លន់ នល់ ឱ្យតែងតាំង អគ្គមេបញ្ជាការកងទ័ពម្នាក់ ជា អ្នកទទួល ខុសត្រូវ ដាច់មុខ ក្នុង កិច្ចការ ប្រតិបត្តិការសឹក ដែល សព្វថ្ងៃនេះ លោក លន់ នល់ គាត់ យកមក កាន់កាប់ ហើយ គ្មាន នរណា អាច ត្រួតពិនិត្យ កិច្ចការនោះបានឡើយ ដូចយ៉ាង បរាជ័យ នៃ ប្រតិបត្តិការ សឹក ចេនឡា ទី២, តើ អ្នកណា ជា អ្នកទទួលខុសត្រូវ ក្នុង វិស័យ យោធា ?

បីបួនថ្ងៃក្រោយមក លោក Swank សូមជួប ទ្រង់ សិរិមតៈ ម្ដង ទៀត ហើយ ជំរាបទ្រង់ថា លោក លន់ នល់ សុខចិត្ត តែងតាំង អគ្គនាយសេនាធិការ និង អគ្គមេបញ្ជាការ ដោយ បានស្នើ ឈ្មោះ ឧត្ដមសេនីយ ថាបណ្ណ ង៉ិន, ខ្ញុំ ចង់សួរទ្រង់ថា តើ ទ្រង់ មាន ឈ្មោះ ឧត្ដមសេនីយ ណាម្នាក់ ស្នើ ដែរឬទេ ? ទ្រង់ សិរិមតៈ បានស្នើ ឈ្មោះ ឧត្ដមសេនីយទោ ស៊ូស្ដែន ហ្វែណង់ដែស[30]

---

30 ឧត្ដមសេនីយ ស៊ូស្ដែន ហ្វែណង់ដែស កើតនៅថ្ងៃ ទី២៨ វិច្ឆិកា ឆ្នាំ ១៩២៣ នៅខេត្តពោធិ៍សាត់។ បុព្វបុរស របស់លោក មកពីប្រទេស ហ្វីលីពីន ដែលមាន ដើមកំណើត ជា ព័រទុយហ្គោ។ លោក បញ្ចប់ សិក្សា នៅ

# ម្ដេចក៏ សាធារណរដ្ឋខ្មែរ ?

## ការប្រទាញប្រទង់គ្នា

ដែល ទ្រង់ យល់ឃើញ ថា ជា ទាហានម្នាក់ មាន គតិ សេរី និង ឯករាជ្យ សំរាប់ ពិភាក្សា ជាមួយ លោក លន់ នល់ ក្នុង កិច្ចការ យោធា។ ចំណែក ឧត្ដមសេនីយ ថាបណ្ណ ងិន លោក លន់ នល់ មាន ឥទ្ធិពលច្រើនណាស់ ទៅលើរូបលោក ដែល អាចទុកជា ចំណុចខ្សោយមួយ នៅក្នុង កិច្ចការយោធា។ នៅចុងបញ្ចប់ លោក លន់ នល់ ជ្រើសយក ឧត្ដមសេនីយទោ ស៊ូស្ដែន ហ្វែណង់ ដែស, សំនួរសួរថា តើ ដោយសារលោក មាន សម្ពាធ ពី សហរដ្ឋ អាមេរិក ឬ លោក ស្ដាប់តាម យោបល់ របស់ទ្រង់ សិរិមតៈ ?

---

វិទ្យាល័យ ស៊ីសុវត្ថិ (classe terminale) ហើយ ចូល សិក្សា ក្នុង សាលា នាយទាហាន ជំនាន់ទី២ នៅ ឆ្នាំ ១៩៤៦។ នៅឆ្នាំ ១៩៤៩ បានមក សិក្សា ក្នុង សាលា នៃ អនុវត្តិ (école d’application d’infanterie à Coëtquidan) នៅ ស្រុកបារាំង។ នៅឆ្នាំ ១៩៥៣ ក្នុង ឋានន្តរស័ក្តិ ជា អនុសេនីយឯក បានមក សិក្សា នៅ សាលា នាយសេនាធិកា នៅ ប្រទេសបារាំង។ នៅឆ្នាំ ១៩៥៨ បានមកសិក្សា ជា ម្ដងទៀត នៅ ស្រុក បារាំង ក្នុង សាលា ជាន់ខ្ពស់ នៃ សង្គ្រាម។ ដំណែង ដែល លោក ធ្លាប់ កាន់ : ១៩៤៩ ក្នុង ឋានន្តរស័ក្តិ អនុសេនីយទោ ជា នាយកងអនុសេនា ធំ នៃ កងវរសេនាតូច លេខ២ (B.C.C.)។ នៅឆ្នាំ ១៩៥១ ជា នាយក សាលា នៃ នាយទាហាន កងតម្រួត នៅស្រុក ថ្ពក ក្នុង ខេត្ត កំពង់ ចាម។ នៅឆ្នាំ ១៩៥៤ ជា នាយកងវរសេនាតូច។ នៅឆ្នាំ ១៩៥៤ ជា នាយខុទ្ទកាល័យ នៃ ក្រសួង ការពារជាតិ បន្ទាប់មក ជា នាយ ការិយាល័យ ទី៣ នៃ អគ្គសេនាធិការ កងខេមរៈភូមិន្ទ។ នៅឆ្នាំ ១៩៦១ វរៈសេនីយទោ ជា នាយតំបន់យោធា ទី២។ នៅឆ្នាំ ១៩៦៧ វរសេនីយឯក ជា រដ្ឋលេខាធិការ ក្រសួង សន្តិសុខជាតិ។ នៅឆ្នាំ ១៩៧០ ឧត្ដមសេនីយត្រី ជា នាយតំបន់យោធា ទី៣។ នៅឆ្នាំ ១៩៧២ ឧត្ដមសេនីយឯក ជា អគ្គនាយសេនាធិការ និង អគ្គមេបញ្ជាការ កងទ័ពជាតិខ្មែរ។ ១៩៧៥ ជា ជនភៀសខ្លួន នៅស្រុកបារាំង, លោក ទទួល អនិច្ចកម្ម នៅឆ្នាំ ២០០៦ នៅស្រុកបារាំង។ ខ្ញុំ ជា អ្នក ធ្វើវិប្បយោគកថា (សុន្ទរកថា ថ្លែង ជា កិត្តិយស ចំពោះសពលោក)។

# ម្ដេចក៏ សោធនារណរដ្ឋខ្មែរ ?

## ការប្រែនាញប្រែនចំន្លា

នៅពេលនោះ សហរដ្ឋអាមេរិក ចង់ឱ្យខ្មែរ មាន មេទ័ព ម្នាក់ មាន ការពិសោធ នៅលើ សមរភូមិ, មាន យុទ្ធវិជ្ជា ខ្ពង់ខ្ពស់ និង មាន គំនិត ឯករាជ្យ និង សេរី ដើម្បី គ្មោរ[31] កិច្ចការ យោធា ជាមួយ នរបតី នោយបាយ។ ឧត្តមសេនីយទោ ស៊ូស្ដែន ហ្វែណង់ដែស ជា ទាហាន (soldat) និង នាយយោធា (chef militaire) ម្នាក់ ត្រូវតាម លក្ខណៈវិនិច្ឆ័យនោះ ហើយ ទន្ទ្បីករណ៍[32] របស់ទ្រង់ សិរិមតៈ ក៏ល្បួងចិត្ត សហរដ្ឋអាមេរិក ខ្លះដែរ។ ទោះបី ទ្រង់ សិរិមតៈ មាន ថ្នាំងថ្នាក់ចិត្តបន្តិច លើ របត់ នៃ គំនិតនយោបាយ របស់លោក លន់ នល់ តែ មិត្តភាព របស់ទ្រង់ ចំពោះ នរនោះ នៅ ខ្ជាប់ខ្ជួន ជានិច្ច ដូចយ៉ាងនៅពេល ដែល លោក លន់ នល់ ឈរឈ្មោះ ជា បេក្ខជន ក្នុងការបោះឆ្នោត ជ្រើសរើស ប្រធានាធិបតី, ថ្វីបើ ទ្រង់ សិរិមតៈ ធ្លាប់ប្រកាស ថា ទ្រង់ ឈប់ ធ្វើនយោបាយ តែ ទ្រង់ ទទួលយល់ព្រម តាមសំណើរ របស់ លោក លន់ នល់ ធ្វើ ជា ទីប្រឹក្សា ពិសេស របស់លោក ដើម្បី បង្ហាញ នូវ មេត្រីភាព ជា គី[33] និង ការគាំពារ បេក្ខភាព របស់ មិត្តភក្តិផង។

---

31 គ្មោរ : កិ. រិះរមើល, គិតលៃលក។
32 ទន្ទ្បីករណ៍ : សេចក្ដីសំអាង។
33 គី : ន. ភ័ស្តុតាងដែលមាន, ប្រាកដ។

# ម្ដេចក៏ សាធារណរដ្ឋខ្មែរ?

## ការប្រនាញប្រនង់គ្នា

### ការបោះឆ្នោត

### ការបោះឆ្នោត ជ្រើសរើស ប្រធានាធិបតី

មាន បេក្ខជនបីនាក់ ចូលប្រកួត គឺ លោក លន់ នល់, អ៊ិន តាំ និង កែវ អាន។

**លន់ នល់** ជា បេក្ខជន នៃ សាធារណរដ្ឋខ្មែរ គឺ ថា នៅក្នុង ស្ថានភាពដូចដដែល (statu quo) ក្នុង គោលគំនិតថម ចញ្ចឹមថែរក្សា របបនេះ ឱ្យមាន និពទ្ធជីវិត[34] (vie permanente) នៅក្នុង ប្រជាជាតិខ្មែរ។ សាធារណរដ្ឋខ្មែរ ចំពោះលោក គឺ ជា ផ្កាល សំរាប់ សតិមន្ត[35] ក្នុង តម្លៃ ‹ខ្មែរថ្មី› ជា ពន្ធមន្ត[36] ខ្មែរ មហានគរ។ ‹ខ្មែរថ្មី› ផ្អែកលើ គុណសម្បត្តិ សាធារណៈ គឺ ប្រជាជន មានបញ្ញា, គុណសម្បត្តិ ប្រជាធិបតេយ្យ គឺ របប សាធារណរដ្ឋ ដែល មាន ប្រជាពលរដ្ឋ ជា អធិបតី។ ហើយ អធិបតេយ្យភាព ដែល ជា អំណាចកំពូល របស់រដ្ឋ ជា របស់ ប្រជាជាតិខ្មែរ ដែល គ្មាននរណា យកធ្វើជាកម្មសិទ្ធិ ផ្ទាល់ខ្លួនបានឡើយ។

**អ៊ិន តាំ** ជា បេក្ខជន យក ជម្រើស កណ្ដាល និង ស្វែងរក ការផ្សះផ្សាជាតិ ជាមួយ សម្ដេច សីហនុ ដោយគ្មាន ខ្មែរក្រហម។ ចំពោះលោក ប្រសិនបើ សម្ដេច យល់ព្រម វាច្បាស់ ជា ពួក ខ្មែរ

34 និពទ្ធជីវិត : ជីវិតដែលគេធ្វើជាប់ហូរហែមិនដាច់, ជីវិតជានិច្ច។
35 សតិមន្ត : អ្នកមានស្មារតី។
36 ពន្ធមន្ត : អ្នកមានពូជពង្ស។

# ម្ដេចក៏ សោធារណរដ្ឋខ្មែរ ?

## ការប្រទាញប្រទង់គ្នា

ក្រហម បាត់ ទំនុកបម្រុង នយោបាយ ដើម្បី បន្ត ធ្វើការតស៊ូ អាវុធ ក្នុងនាម បដិវត្តន៍ ផ្តាច់ឬស (révolution radicale) គឺ វាគ្រាន់តែ ជា វិធីសាស្ត្រ កុម្មុយនិស្ត ប៉ុណ្ណោះ ដែល វាគ្មាន មូលដ្ឋាន អ្វី បន្តិចសោះ នៅក្នុង សង្គមខ្មែរ។ បដិវត្តន៍នោះ គឺ ប្រៀបផ្ទឹម នឹង ផ្ទឹង សង្គមខ្មែរ ដោយ ប្តូរនឹង សង្គម កុម្មុយនិស្ត ដែល ជា កំបោក។ បើលោក ដាប់ឆ្នោត លោក នឹងធ្វើ សង្គមខ្មែរ ឱ្យផ្ទើយ[37] ដូច សម័យស្រុកខ្មែរ ធ្លាប់ រុងរឿង។ លោក អ៊ិន តាំ ថា កែវ អាន ភ្លយ[38] ទុកខ្លួន ជា មនុស្សថ្មី តែ យក មគ្គ[39] ចាស់ មក សន្យា គឺ ទ្រឹស្តី កុម្មុយនិស្ត ដូច ពួក ខ្មែរក្រហម។ ត្រូវដឹង ថា សហរដ្ឋអាមេរិក ទុក លោក អ៊ិន តាំ ជា មនុស្ស ស្អាតស្អំ បំផុត ក្នុង ចំណោម នយជនខ្មែរ តែ លោក មាន កង្វះ សេចក្តីឈ្លាសវៃ ក្នុង កិច្ចការ ការបរទេស។

**កែវ អាន** តាំងខ្លួន ជា បេក្ខជន នៃ «បុនក្ការ[40]» និង ជា ប្រមុខ នៃ យុវជន ផងដែរ។ លោក និយាយ ភោរភារ ថា លោក លន់ នល់, ទ្រង់ សិរិមតៈ លោក អ៊ិន តាំ និង លោក ស៊ឹង ង៉ុក ថាញ់ សុទ្ធ ជា មនុស្ស ហួសសម័យ ដែល គួរ យកទៅតាំងនៅ សារមន្ទីរ។ ដូច្នេះ ទ្រឹស្តី ‹បុនក្ការ› ត្រូវការ មនុស្សថ្មី មិនដូច

---

37 ផ្ទើយ ឬ ភើយ : ធ្វើឱ្យងើយ, ចាប់លើកឱ្យងើយឡើងលើ។
38 ភ្លយ : និយាយឥតបើគិត, ចេះតែរបូតថាតាមតែរួចពីមាត់។
39 មគ្គ : ន. ផ្លូវប្រតិបត្តិ, លំអាន។
40 បុនក្ការ : ការធ្វើសារជាថ្មី។

# ម្ដេចក៏ សាធារណរដ្ឋខ្មែរ ?

## ការប្រែធាញប្រែធង់គ្នា

ទ្រឹស្ដី « ខ្មែរថ្មី » របស់លោក លន់ នល់ ដែល ស្មើ ដោយ មនុស្សហួសសម័យ។ មែនទែន ជ្រើសរើស លោក លន់ នល់ គឺ ជាជម្រើស នៃ អចលកម្ម នៃ សាធារណរដ្ឋខ្មែរ ដែល មាន លោក លន់ នល់ ជា អវតា។ ដូច្នេះ ត្រូវចាំបាច់ សាង សាធារណរដ្ឋថ្មី ជាមួយនឹង មនុស្សថ្មី ដែល មានគាត់ (កែវ អាន) ជា អវតា។ លោក កែវ អាន បន្ត និយាយ ថា ការផ្ដាច់ ពី របប រាជានិយម គឺ ជា ផ្លូវ នៃ សង្គ្រោះជាតិ ដែល រស់នៅក្នុង អត្ថង្គត ដូច្នេះ មិនត្រូវ ផ្ទៀតឱកាស យក ការប្ដូរ នៃ របប មកធ្វើ ជា ឧបករណ៍ បំរើ មហិច្ឆិតា នៃ អំណាច តែ ផ្ទុយទៅវិញ ត្រូវយកមកធ្វើ ជា មធ្យោបាយ សំរាប់ កសាង ‹បុនក្ការជាតិ› (renouveau national) ដែល ត្រូវការ កែជាថ្មី នូវ កង្វះ គុណភាព ឬ អសមត្ថភាព នៃ ពួក អ្នកដឹកនាំជាតិ ហួសសម័យ និង ប្ដូរ សតិសម្បជញ្ញៈ នៃ ប្រជាពលរដ្ឋ ដែល ទុកខ្លួន ជា ខ្ញុំបំរើ ឱ្យ មាន មនសិការ ជា អធិបតី។ ដូច្នេះ ការប្ដូរនោះ ត្រូវ មាន លក្ខណៈ ជា ការផ្លាស់ ផ្ដាច់ប្ដូរ (changement radicale) គឺថា ត្រូវដូរ ប្រព័ន្ធ ដឹកនាំទាំងអស់ មិននៅត្រឹមតែ លុបបំបាត់ចោល នៃ របប រាជានិយម តែឈ្មោះនោះឡើយ។

គេអាច សួរ ជាសំនួរ ថា ចុះហេតុអ្វី បានជា ទ្រង់ សិរិមតៈ មិនឈរ ជា បេក្ខជន ? សំនួរនេះ ក៏អាចសួរ ចំពោះលោក ស៊ឹង ង៉ុកថាញ់ ផងដែរ។

# ស្ដេចក៏ សាធារណរដ្ឋខ្មែរ ?

## ការប្រទាញប្រទង់គ្នា

ចំពោះទ្រង់ សិរិមតៈ ទ្រង់ មាន សតិសម្បជញ្ញៈ ថាទ្រង់ជា ស្ដេច ដូច្នេះ ការចូលប្រកួតនោះ គឺ ជា អនេសនៈ[41] ដែល អាច ប្រជាពលរដ្ឋ ទុកជា ការបង្កហេតុ នៅក្នុង បរិបទ នៃ ការបង្កើត សាធារណរដ្ឋខ្មែរ ដែល ជា របប ទុក ស្ដេច ជា និមិត្តរូប ផ្ដាច់ការ និង ហួសសម័យ។ មួយវិញទៀត ទ្រង់ ទុក លោក លន់ នល់ និង ទ្រង់ ជា អនុគាមី[42] នៅក្នុង ដំណើរ នៃ ការកសាង សាធារណរដ្ឋខ្មែរ ដូច្នេះ វា គ្មាន ហេតុផលអ្វី ដែល ទ្រង់ ត្រូវ ឈរ ឈ្មោះ ប្រឆាំងនឹងលោក លន់ នល់ នោះឡើយ។ សួរបន្ត ទៀត ថា ចុះបើ លន់ នល់ មិន ឈរ ឈ្មោះ ជា បេក្ខជន តើ ទ្រង់ សិរិមតៈ នឹងអាច ឈរ ឈ្មោះ ដែរឬទេ ? ចម្លើយ គឺ គ្មានទេ, តែ ទ្រង់ នឹងលើកទឹកចិត្តលោក ចេង ហេង ឱ្យឈរ ជា បេក្ខជន ព្រោះ នរនោះ គាត់ មាន គោលការណ៍ នយោបាយ ប្រហាក់ប្រហែលគ្នានឹងទ្រង់។ មួយវិញទៀត បើគ្មាន បេក្ខភាព នៃ លោក លន់ នល់, លោក ចេង ហេង ក៏មាន គោលចំណង់ ចង់ ឈរ ឈ្មោះ ផងដែរ។

ចំណែកលោក ស៊ឹង ង៉ុក ថាញ់ វិញ បន្ទាប់ពីលោក បាន ធ្វើ រដ្ឋមន្ត្រី ទី១ ក្នុងមួយរយៈពេលមក លោក យល់ឃើញថា លោក គ្មាន ចន្ទល់ នៃ ប្រជាពលរដ្ឋ សំរាប់ ទ្រទ្រង់ បេក្ខភាព របស់

---

41 អនេសនៈ ឬ អនេសនា : ន. ការស្វែងរកពុំត្រូវតាមបែបបទ។

42 អនុគាមី : អ្នកទៅជាមួយគ្នា។

## ម្ដេចក៏ សោធារណរដ្ឋខ្មែរ ?

### ការប្រណាញប្រនន់គ្នា

លោកនោះឡើយ វៀរលែងតែ ក្រុម ហង្ស ធុន ហាក់ និង លន់ ណុន ដែលមាន ទំនាក់ទំនង ជាមួយលោក ជា ការរកប្រយោជន៏ តែប៉ុណ្ណោះ។ វិច្ឆេទកម្ម មកលើរូបលោក[43] ជា សញ្ញាមួយ ថា ក្រុមនោះ បោះបង់លោកចោល ដូច្នេះ ប្រសិនបើលោក បន្ត ធ្វើសកម្មភាព នយោបាយ និង រស់នៅស្រុកខ្មែរ លោក ច្បាស់ ជាមាន គ្រោះថ្នាក់ដល់ជីវិត ជាពុំខាន។ គឺ អាស្រ័យហេតុនេះឯងដែលលោក សម្រេចចិត្ត វិលត្រឡប់ ទៅរស់នៅ កម្ពុជាក្រោមវិញ។ ត្រូវដឹងថា ការប៉ុនប៉ង ចុងក្រោយបង្អស់ របស់ក្រុម ហង្ស ធុន ហាក់ គឺ ស្នើដល់លោកលោក លន់ នល់ ឱ្យតែងតាំងលោក ស៊ឹង ង៉ុក ថាញ់ ជា អនុប្រធានាធិបតី តែត្រូវបានលោក លន់ នល់ បដិសេធ។ មាន ពាក្យចចាមអារ៉ាម ថា តំណែងនេះ លោក លន់ នល់ ចង់រក្សាទុកជូនទ្រង់ សិរិមតៈ តែ ទ្រង់ សិរិមតៈ បដិសេធ។

គួរដឹងដែរថា លោក ស៊ឹង ង៉ុក ថាញ់ ត្រឡប់មកធ្វើនយោបាយនៅស្រុកខ្មែរវិញ គ្មានការគាំទ្រពី សហរដ្ឋអាមេរិកនោះឡើយ តែ ដោយសារគេ មិនចង់ ជ្រៀតជ្រែកចូល ក្នុងកិច្ចការនយោបាយខ្មែរ ដូច្នេះ រឿងរ៉ាវ នៅក្នុងផ្ទៃក្នុងខ្មែរ ជា បញ្ហា

---

43 គឺលោក លន់ ណុន ជា អ្នកបញ្ជាឱ្យដាក់គ្រាប់បែកផ្លាស់ស្ទិក សំលាប់លោក ស៊ឹង ង៉ុក ថាញ់ ព្រោះ លោក ស៊ឹង ង៉ុក ថាញ់ ដឹងរឿងច្រើន ពីអំពើ ទុច្ចរិត របស់គាត់ ហើយ ភ័យខ្លាចលោក ស៊ឹង ង៉ុក ថាញ់ យកទៅជំរាប់ លោក លន់ នល់ និង ឯកអគ្គរដ្ឋទូតអាមេរិកាំង។

## ការប្រទាញប្រទង់គ្នា

របស់ខ្មែរ ដែលខ្មែរ ត្រូវដោះស្រាយ ដោយខ្លួនឯង។ ត្រូវដឹងថា ការប៉ុនប៉ង របស់លោក Emory Swank, ឯកអគ្គរដ្ឋទូត អាមេរិកាំង, ថា ការផ្ដួចផ្ដើមផ្ទាល់ខ្លួន របស់លោក ចង់ឱ្យទ្រង់ សិរិមតៈ ជំនួស លោក លន់ នល់ ត្រូវបាន ក្រសួង ការបរទេស អាមេរិកាំង ស្ដីបន្ទោសលោក[44]។

### ការបោះឆ្នោត រើសតំណាងរាស្ត្រ

មុនបោះឆ្នោត ជ្រើសរើសតំណាងរាស្ត្រ ទ្រង់ សិរិមតៈ បាន ប្រឹក្សា ជាមួយលោក លន់ នល់ ស្ដីពី ការបង្កើត គណបក្សនយោបាយ។ ទ្រង់ សួរ ទៅកាន់លោក លន់ នល់ ថា តើ គាត់ ចង់ បង្កើត គណបក្ស នយោបាយដែរឬទេ ? នរនោះ ឆ្លើយថា

---

44 លោក បានជំរាបរឿងនេះដល់ទ្រង់ សិរិមតៈ នៅពេលមុននឹងចាកចេញពីស្រុកខ្មែរ។ ហើយ លោក បន្ថែមថា ទ្រង់ បដិសេធ មិនព្រមជំនួសលោក លន់ នល់ ជា ការសម្រេចចិត្ត ល្អពិត សំរាប់ សីលធម៌ របស់ទ្រង់ តែ វា គ្មាន ប្រយោជន៏អ្វី សំរាប់ នយោបាយនោះឡើយ។ អ្នកកាន់តំណែងមុនលោក, Mike Rives ធ្វើចំណារមួយជូនលោក ថា លោក លន់ នល់ រស់នៅក្នុង ពិភពស្រមើលស្រមៃ គឺ គិតតែ ចង់កសាងបារមី ឱ្យដូចនៅសម័យអង្គរ ជាង គិត ច្បាំង ការពារជាតិខ្មែរ ដែល កំពុង វាយប្រហារដោយ ពួក យួនកុម្មុយនិស្ដ។ ហើយ លោក Mikes Rives ធ្វើសេចក្ដីសន្និដ្ឋាន ថា បញ្ហាប្រញាប់ ដែលត្រូវដោះស្រាយ គឺ ធ្វើយ៉ាងណាឱ្យលោក លន់ នល់ វិលត្រឡប់មករស់នៅក្នុងពិភពពិត គឺ ស្រុកខ្មែរកំពុង មាន សង្គ្រាម។ លោក Emory Swank ធ្វើសេក្ដីសន្និដ្ឋាន បែបជាការបន្ទោសដល់ទ្រង់ សិរិមតៈ ថា លោក មិនយល់ពីការបដិសេធ របស់ទ្រង់ មិនហ៊ាន អាកាត់ ដោះស្រាយ បញ្ហា ពិការភាព របស់លោក លន់ នល់ នៅក្នុង បរិបទ ដ៏ធ្ងន់ធ្ងរ នៃ ស្រុកខ្មែរ ដែល ត្រូវការ មាន អ្នកដឹកនាំ ហ្វាហាប់ និង មាន សេចក្ដីឈ្លាសវៃ ក្នុង កិច្ចការ នយោបាយ។

# ម្ដេចក៏ សាធារណរដ្ឋខ្មែរ ?

## ការប្រណាញប្រឧំត្អ

លោក មិនមានបំណង ធ្វើ ជា ប្រធាន គណបក្សនោះឡើយ ព្រោះលោក ចង់នៅក្រៅពី ការពិភាក្សា នយោបាយ រវាង គណបក្ស នយោបាយ។ ទ្រង់ សិរិមតៈ ក៏មានយោបល់ ដូចលោក នល់ នល់ ដែរ តែ ទ្រង់ បញ្ជាក់ថា ពួក អ្នក មាន ចរន្ត នយោបាយ ដូចទ្រង់ គេនឹងនាំគ្នាបង្កើត គណបក្ស បើលោក លន់ នល់ មិនបង្កើត ហើយ ដាក់ឈ្មោះ ថា ‹គណបក្ស សាធារណរដ្ឋ[45]› តើ នល់ឯង មាន យោបល់បែបណា ? លោក នល់ នល់ ឆ្លើយថា ការណ៍នេះ វា ជា សិទ្ធិសេរីភាព របស់ខ្មែរម្នាក់ៗ ដូច្នេះ វា គ្មាន ទំនើស អ្វីទេនឹងគំនិត របស់លោកនោះឡើយ។ នៅ ពេលនោះដែរ លោក ហង្ស ធុន ហាក់ និង លោក លន់ ណុន បាននាំគ្នាបង្កើត គណបក្សនយោបាយ ឈ្មោះ ‹គណបក្ស សង្គមសាធារណរដ្ឋ›, ចំណែក លោក អ៊ិន តាំ ក៏បង្កើត គណបក្ស ឈ្មោះ ‹គណបក្ស ប្រជាធិបតេយ្យ›, ហើយ លោក អះអាង ថា គណបក្សនេះ ជា ការបន្ត សកម្មភាព ពី គណបក្ស ប្រជាធិបតេយ្យ នៅ ទសវត្ស ៤០។

នៅឆ្នាំ ១៩៧២ ខែ កញ្ញា នៅពេលបោះឆ្នោត រើស តំណាងរាស្ត្រ គណបក្ស សាធារណរដ្ឋ និង ប្រជាធិបតេយ្យ បានធ្វើ ពហិការ ដោយ យល់ឃើញ ថា ស្ថានភាព ប្រទេស ឥឡូវនេះ ពុំអាច ធានា នូវ ការបោះឆ្នោត នៅក្នុង លក្ខខណ្ឌ ប្រជាធិបតេយ្យ បាននោះ

---

45 គណបក្ស សាធារណរដ្ឋ មាន លោកឪពុកខ្ញុំ ជា អគ្គលេខាធិការ។

# ម្ដេចគឺ សាធារណរដ្ឋខ្មែរ ?

## ការប្រណាញប្រនចំគ្នា

ឡើយ។ ដូច្នេះ គណបក្ស ដែល ធ្វើការ បោះឆ្នោត មានតែ គណបក្ស សង្គម សាធារណរដ្ឋ និង គណបក្ស តូចមួយ ដែល លោក លន់ ណុន បង្កើតឱ្យមាន គឺ ‹គណបក្ស ប្រជាជន› ដើម្បី ឱ្យការបោះឆ្នោតនោះ មាន លក្ខណៈ ប្រជាធិបតេយ្យ និង ពហុបក្ស។ ចំពោះ គណបក្ស សង្គម សាធារណរដ្ឋ, ការបោះឆ្នោតនោះ មានសារៈសំខាន់ណាស់ ព្រោះ សាធារណរដ្ឋខ្មែរ ត្រូវចាំបាច់មាន ស្ថាប័នជាតិ គ្រប់គ្រាន់ ដើម្បី ឆ្លើយតបនឹង ការទាមទារ កៅអីតំណាង នៅ អង្គការ សហប្រជាជាតិ ពីសំណាក់ រាជរដ្ឋាភិបាល បង្រួបបង្រួមជាតិ ដឹកនាំដោយ សម្ដេច សីហនុ។

លទ្ធផល នៃ ការបោះឆ្នោត គឺ គណបក្ស សង្គម សាធារណរដ្ឋ ទទួលបាន អាសនៈ ១២៦ គឺ ទាំងអស់។ ដូច្នោះឯង ដែល ក្រុម ហង្ស ធុន ហាក់ ឬ ភ្នំដងរ៉ែក ទទួលបានជ័យជំនះ លើ សត្រូវនយោបាយ របស់ខ្លួន។ បន្ទាប់ពីលោក ស៊ីង ង៉ុក ថាញ់ លាលែងពីតំណែង រដ្ឋមន្ត្រី ទី១, លោក លន់ នល់ បានតែងតាំងលោក ហង្ស ធុន ហាក់ ជា រដ្ឋមន្ត្រី ទី១, ចំណែក លោក លន់ ណុន ត្រូវបានលោក ហង្ស ធុន ហាក់ តែងតាំង ជា រដ្ឋមន្ត្រី ក្រសួង កំណែន ទូទៅ និង ផ្គត់ផ្គង់។ រដ្ឋាភិបាលនោះ មានរូបភាព ជារដ្ឋាភិបាល ដែលប្រកាន់បក្សពួកនិយម ដែល នាំបង្កើត អាយតភាព[46] នយោបាយ រវាង នយជន ទាំងឡាយ។ លើសពីនេះ

[46] អាយតភាព ៖ ភាពតានតឹង។

# ស្ដេចពាក់ សាធារណរដ្ឋខ្មែរ ?

## ការប្រែធាញប្រែខច់ផ្កា

ទៀត, លោក លន់ ណុន សាបព្រោះ នូវ អំពើភេរវកម្ម ប្រឆាំង នឹង គូសត្រូវ នយោបាយ របស់គាត់ ដែលនាំឱ្យរូបគាត់ ក្លាយ ជា ជនភយង្ករ[47] នៅក្នុង សាធារណរដ្ឋខ្មែរ។ ឧទាហរណ៍ នៅថ្ងៃ ទី១៧ កុម្ភៈ ១៩៧៣, នៅពេលព្រឹកព្រហ៊ាម មាន កងពិសេស (commando) លួចចូល ទៅក្នុង មហាវិទ្យាល័យ គរុកោសល្យ ដើម្បី រំដោះ ចំណាត់ខ្នាំងមួយក្រុម[48] ដែល ពួក និស្សិត បះបោរ ចាប់ ទុក, តែនៅពេលនោះ មាន ផ្ទុះអាវុធ ព្រោះ ពួក និស្សិត បះបោរ មាន អាវុធ ការពារខ្លួន។ នៅក្នុងចំណោម និស្សិត មាន ស្លាប់ ២នាក់ និង របួស មួយនាក់។ ភយន្ដរាយនោះ ជា ទង្វើ របស់ លោក លន់ ណុន ដូចគ្នានឹង ការប៉ុនប៉ង ធ្វើឃាតលោក ស៊ីង ង៉ុក ថាញ់ ផងដែរ។

នៅថ្ងៃ ទី ១៧ កុម្ភៈ ឆ្នាំ ១៩៧៣ នោះដែរ, នៅពេលរសៀល, អនុ សេនីយទោ សូ បុត្រា អាកាសយានិក យន្ដហោះ T28[49] បាន បើកយន្ដហោះ ទម្លាក់ គ្រាប់បែក ពីរគ្រាប់ ទៅលើ វិមាន ប្រធា នាបតី ចំការមន តែ មិនចំលើ ទីកន្លែង រស់នៅ របស់លោក លន់ នល់ ដូច្នេះ វាគ្មាន ប៉ះពាល់ ដល់ សុវត្ថិភាព របស់លោក នោះទេ តែ បន្ទាយ កងអង្គរក្ស របស់លោក ត្រូវបាន

---

47 ភយង្ករ : (ភយង់-ក) គុ. ដែលគួរឱ្យខ្លាច។
48 ជា បុគ្គលិក សំខាន់ៗ របស់ មហាវិទ្យាល័យ។
49 សូ បុត្រា : ជា កូនប្រុសរ របស់សម្ដេច សីហនុ ជា ស្វាមី របស់ ព្រះអង្គ ម្ចាស់ក្សត្រី បទុម បុប្ផា។

# ម្ដេចក៏ សោធនាស្ដេចខ្មែរ ?

## ការប្រែឈាញប្រែនខំត្ដា

គ្រាប់បែកទី១ កំទិចខ្ទេចអស់។ ព្រឹត្តិការណ៍នោះ ញុំាងឱ្យលោក ហង្ស ធុន ហាក់ ស្នើដល់ រដ្ឋសភា ចាត់វិធានការ ផ្តន្ទាទោស ដល់ រាជវង្សានុវង្ស ដូចជា ត្រូវដាក់ ទ្រង់ សិរិមតៈ នៅក្រោម ការឃុំខ្លួនក្នុងផ្ទះ។ ទោះបី គ្មាន ការអនុញ្ញាត ពី រដ្ឋសភា លោក លន់ ណុន បាន បញ្ជាឱ្យ កងទ័ព របស់គាត់ យក រថក្រោះមួយ គ្រឿង មកដាក់ក្បែរ ផ្ទះទ្រង់ សិរិមតៈ។ ផ្ទះ របស់ ឪពុកខ្ញុំ ក៏ត្រូវ បានលោក លន់ ណុន យក រថក្រោះមួយគ្រឿង មកចតនៅពី មុខផ្ទះតែម្តង។ ទង្វើនោះ គឺ គាត់ ចង់ សម្លុតចិត្ត ទ្រង់ សិរិម តៈ និង លោក ឪពុកខ្ញុំ ដែល គាត់ទុក ជា សត្រូវ នយោបាយ ដាច់ខាត របស់គាត់។ អាកប្បកិរិយាតិក្រម[50] របស់លោក លន់ ណុន វា ក្លាយ ជាប្រធានបទ នៃ ការសន្ទនា របស់ ខ្មែរ គ្រប់ មជ្ឈដ្ឋាន ដែលនាំ រំខាន ដល់ សកម្មភាព របស់ រដ្ឋាភិបាល ដែល ជំរុញគាត់ ឱ្យដកខ្លួនចេញពី គណរដ្ឋមន្ត្រី នៅថ្ងៃ ទី៤ មេ សា តែ ស្អែកឡើង ស្រាប់តែ គណកម្មាធិការ ការពារជាតិ សម្រេចចិត្ត បញ្ជូន សមាជិក ៩ នាក់ នៃ រាជវង្សានុវង្ស ទៅ តុលាការយោធា មាន ជា អាថ៌ ទ្រង់ រណឬទ្ធិ។ សួរថា តើ នរណា ជា អ្នកបញ្ជា ឱ្យធ្វើ ? តើ លោក ហង្ស ធុន ហាក់ ជា រដ្ឋមន្ត្រី ទី ១ ជា អ្នកបញ្ជា ឱ្យធ្វើ (donneur d’ordre) ឬ ក៏ជា បញ្ជា របស់លោក លន់ នល់ ? មិនថា ជា នរណាឡើយ តែ ទង្វើនោះ វា មាន រូប

50 អាកប្បកិរិយាតិក្រម : អាកប្បកិរិយា អរភ័យដរាប អរព្រះតែប្រាប ភ័យព្រោះគេដឹង។

# ម្ដេចក៏ សាធារណរដ្ឋខ្មែរ ?

## ការប្រទាញប្រទង់គ្នា

ភាព ជា ការសងសឹង សុទ្ធសាធ នៅក្នុង មតិសាធារណជន ដែល ធ្វើឱ្យ រដ្ឋាភិបាល គ្មាន ប្រជាប្រិយភាព ដែល តម្រូវឱ្យ លោក ហង្ស ធុន ហាក់ លាលែង ពីតំណែង រដ្ឋមន្ត្រី ទី១ នៅថ្ងៃ ទី១៧ មេសា។ ហើយនៅថ្ងៃ ទី២៤ មេសា លោក លន់ នល់ បង្កើត ‹ឧត្តម ក្រុមប្រឹក្សា នយោបាយ› ដែល មានលោក ជា ប្រធាន ប្រមូលផ្តុំ តួឯក សំខាន់ៗ ដូចជា លោក ចេង ហេង ជា អនុប្រធាន និង ទ្រង់ សិរិមតៈ និង លោក អ៊ិន តាំ ជា សមាជិក។ សួរថា ការបង្កើត វាជា វិធានការ សំរាប់ បញ្ចប់ ការប្រទាញប្រទង់គ្នា នោះឬ ?

### សេចក្តីសន្និដ្ឋាន

ជាការពិត កាប្រទាញប្រទង់គ្នា វា មិនមែន ជា អកុសល ដាច់ខាតនោះឡើយ នៅក្នុង គោលការណ៍ នៃ ប្រជាធិបតី, តែ វា កើតឡើង នៅក្នុង បរិបទ មាន សង្គ្រាម។ ក្រុម លោក ហង្ស ធុន ហាក់ និង លន់ ណុន ប្រញាប់ប្រញាល ផ្តើមបង្ករ ជម្លោះ ឥតមានហេតុផល ជាមួយទ្រង់ សិរិមតៈ ព្រោះ ខ្លាចទ្រង់ ឆ្លៀតឱកាស ប្រមូល អំណាច ពី លោក លន់ នល់ ដែល កំពុង មាន ព្យាធិ។ ការសម្រុក ទៅរក អំណាច នៃ ក្រុមនោះ វា មាន រូបភាព ជា ការដណ្តើម អំណាច ពីលោក លន់ នល់ ទៅវិញ ដោយ មិនរវល់គិត ពី កម្មវិបាក នៃ ទង្វើ របស់ខ្លួន គឺ កំទិច សាមគ្គីជាតិ ដែល ប្រជាជាតិ កំពុងត្រូវការ ដាច់ខាត។ មួយវិញទៀត

# ម្ដេចក៏ សោធារណរដ្ឋខ្មែរ ?

## ការប្រែបានញប្រូនចំន្លា

ព្យាធិ របស់លោក លន់ នល់ ជម្រុជគាត់ ទៅក្នុង ពិភព ស្រមើលស្រមៃ នៅក្នុងនោះ វាមិនមានអ្វី ជា ការពិត ដែល វា បំពត់ ចិត្តគំនិត របស់លោក ឱ្យងាកទៅរក ភាពងេងងោង នៃ អំណាច គឺថា ប្រើ អំណាច ដើម្បី ការពារ អំណាចអាត្មា។ អំណាច បែបនោះ នាំឱ្យលោក ស្ថិត នៅ ក្នុង ភាពឯកា ដែល ជា ស្ថានភាព អាចឱ្យ អ្នកអបអម របស់លោក ឆ្លៀត បោយ យក ផលប្រយោជន៍ គ្រប់បែបយ៉ាង។ ដូច្នេះ លោក លន់ នល់ ជា មនុស្សឈើ និង ជា ជនពិការ នាំបង្កើត ពួក អ្នកឆ្លៀត ទាញគុណប្រយោជន៍ពីលោក ច្រើនជាង ពួក អ្នកតស៊ូ ដើម្បី ជួយលោក ក្នុង កិច្ចការជាតិ។ តែ រឿងនោះ វា អាចទុក ជា បរាជ័យ រួមគ្នា របស់ នយជនខ្មែរ គ្រប់ និន្នាការ នយោបាយ ព្រោះ នៅពេលនោះ ពុំអាច ប្ដូរ លោក លន់ នល់ ជនពិការ នៅ ក្នុង គំនិត នៃ ការតស៊ូរួម ដែល ជា សេចក្ដីត្រូវការ នៃ ប្រជា ជាតិ បែរ ជា យក ការប្រយុទ្ធ យក អំណាច ដែល ជា កត្តា នៃ ការបំបែក ជាពួកប្រឆាំងគ្នា នាំបង្កើត ជា លាភផល សំរាប់ សត្រូវជាតិ។ មោហន្ធការ[51] ដូច្នោះ វា ជា កត្តា នៃ បរាជ័យ របស់ សាធារណរដ្ឋខ្មែរ ដែល វា មិនអាចចៀសរួចបាននោះឡើយ៕

[51] មោហន្ធការ : សភាវៈធ្វើឱ្យដូចជាខ្វាក់, ដូចជាសេចក្ដីងងឹតសូន្យ ឈឹងពុំយល់ដឹង។